# ទស្សនាវដ្ដី

# សាស្ត្រាចារ្យ

ផ្សាយ
ចេញ
រាល់
ត្រីមាស
ពី

**សមាគម**
**សាស្ត្រាចារ្យខ្មែរ**

ទីស្នាក់ការ
លេខ ១២៣ **E** វិថីព្រះសីហនុ ភ្នំពេញ



ខែកក្កដា សីហា កញ្ញា

ឆ្នាំ ទី ៥

លេខ
15



ពិធីបុណ្យខួប ទី ៤៣ រំលឹកការប្រសូតនៃ សម្ដេចឪ

(ពិធីបុណ្យខួបទី ១១ រំលឹក ឯករាជ្យជាតិ

# សូមសម្ដេចឪព្រះអង្គទ្រង់មាន ព្រះជន្មរាប់រយព្រះវស្សា !



ព្រះរាជទស្សនកិច្ច នៅឥណ្ឌូណេស៊ី (ពីថ្ងៃ១៤-ដល់២១សីហា ១៩៦៤)



ព្រះរាជទស្សនកិច្ចនៅចិនប្រជាមានិត (ពីថ្ងៃ២៦ កញ្ញា ដល់ថ្ងៃ ៨ តុលា ១៩៦៨)

# ទ្វីបអាស៊ីបានសាមគ្គីគ្នាក្រោកឡើង ការពារទឹកដីរបស់ខ្លួន

ចំពោះអំពើរុករាន នៃ ចក្រពត្តិនិយមអាមេរិក និង បរិវារ

**មាតិកាអត្ថបទ**


○ ការកែទំរង់ខ្លួននឹងវិជ្ជាជីវៈសិក្សា ក

○ វិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់ មិត្តភាពខ្មែរ-សូវៀត ជ

បិត្តគរុកោសល្យ: ○ ការសិក្សានៅប្រទេសជប៉ុន 4

○ ការសិក្សានៅប្រទេសឥណ្ឌូស៊ី 12

វិទ្យាសាស្ត្រនឹងសិល្ប: ○ កំណាព្យ «សិស្សភ្ញាក់រលឹក» 26

○ ទំព័រមួយថ្មីនៃវិទ្យាសាស្ត្រសាកលលោក 28

○ សល្យវិទូចិនបាននេរនៃរបស់កម្មករម្នាក់ដែលបាក់ដាច់ពីគ្នាឱយបានជាប់ឡើងវិញ 32

○ វិទ្យាសាស្ត្រថ្មីៗ . . . 37

កិច្ចការសមាគម ○ មហាសន្និបាតសាមញ្ញឆ្នាំ ១៩៦៤ 44

○ សេចក្តីសំរេចចិត្តនៃមហាសន្និបាតឆ្នាំ ១៩៦៤ 56

○ សេចក្តីថ្វាយព្រះពរសព្ទសាធុការនៃសមាគមសាស្ត្រាចារ្យខ្មែរក្នុងឱកាសពិធីចំរើនព្រះជន្មគំរប់ ៤៣ ព្រះវស្សានៃសម្តេចឪ 59

○ ញត្តិនៃសមាគមសាស្ត្រាចារ្យខ្មែរ 61

○ លិខិតប្រគេនសម្តេចព្រះពោធិវង្សនឹងលិខិតឆ្លើយតប 64

យើងឆ្លើយឆ្លងគ្នា

អត្ថបទ-ឯកសារ ○ ប្រធានវិញ្ញាសានៃការប្រឡងប្រជែងជ្រើសរើសនិស្សិតសាស្ត្រាចារ្យ 71

○ របៀបបោះឆ្នោតជ្រើសរើសប្រធានាធិបតីនៅសហរដ្ឋអាមេរិក 78

ជីវភាពមិត្តយើង




*ជាតិស្រាប់ ៗ ក្នុងការរៀនអក្សរនេះ បងប្អូនយើងបានបង្កើតមធ្យោបាយមួយដ៏សំខាន់សំរាប់បណ្តុះបណ្តាលវប្បធម៌ខ្លួនឯងផង សំរាប់បង្កើនកំរិតស្នេហាជាតិផង ហើយសំរាប់រួមចំណែកលើកវប្បធម៌នឹងសេដ្ឋកិច្ចប្រទេសយើងផង ។*

*អាស្រ័យសន្តិភាពខាងក្នុង នឹងសាមគ្គីភាពនៃកូនចៅទាំងអស់ជុំវិញអង្គសម្តេចឪ ឧបសគ្គទាំងឡាយនឹងត្រូវរលាយដូចជាភាពមិនចេះអក្សរ ហើយជោគជ័យទាំងឡាយនឹងប្រមូលបានទៀត ។*

## មិត្តទាំងឡាយ

ប្រទេសយើង ក្នុងការធ្វើបុណ្យរំលឹកខួបទី៤៣នៃការប្រសូតរបស់សម្តេចព្រះអគ្គមគ្គុទ្ទេសក៍ និងរំលឹកខួបទី១០នៃឯករាជ្យជាតិរបស់ខ្លួនយ៉ាងគគ្រឹកគគ្រេងនេះ បានបញ្ជាក់នូវជំហានទៅមុខរបស់ខ្លួនយ៉ាងរលះរលាំង ។ ដោយពីព្រះរាជនយោបាយកែទំរង់សេដ្ឋកិច្ចដែលបញ្ចប់ឆ្នាំ១៩៦៣ និងព្រះរាជនយោបាយត្បិតត្បៀតដែលព្រះអង្គបានសម្ដែងកាលពីខែវិច្ឆិកានេះ ប្រទេសយើងបានស្គាល់នូវការរីកលូតលាស់យ៉ាងសំបើមក្នុងវិស័យវប្បធម៌ ។

យើងជាសាស្ត្រាចារ្យ យើងបានកត់ត្រាទុកក្នុងស្មារតីជានិច្ចនូវព្រះរាជសន្និសីទគរុកោសល្យជាប្រវត្តិនៅព្រះដំណាក់ចំការមន ស្ដីអំពីការកែទំរង់សិក្សាធិការ ដែលត្រូវដើរទៅទន្ទឹមគ្នានឹងការកែទំរង់សេដ្ឋកិច្ច ហើយរាល់គ្នា យើងសុទ្ធតែបានយកអស់កម្លាំងកាយ កម្លាំងប្រាជ្ញា និងកម្លាំងចិត្តមកប្រើដើម្បីជាវិភាគទានសំរេចនូវព្រះតំរិះនេះ ។ មួយឆ្នាំបានកន្លងទៅហើយ ព្រះរាជគតិ«សិក្សាដើម្បីបង្កើនផល»កាន់តែបានចាក់ឫសគល់ក្នុងគ្រប់ស្មារតី រីឯពន្លឺនៃជំនឿលើព្រះរាជគតិនេះក៏កាន់តែបានទូលំទូលាយហើយមាំមួនខ្លាំងឡើងៗ ។

ព្រះរាជតំរិះមួយទៀតដែលធ្វើឲ្យយើងជាសាស្ត្រាចារ្យមានអំនួតជាខ្លាំង គឺការបង្កើតសាកលវិទ្យាល័យថ្មីៗទៀតហើយនិងមហាវិទ្យាល័យជាច្រើន ។ អាស្រ័យសាកលវិទ្យាល័យ៣នេះ សាកលវិទ្យាល័យដែលខ្លឹមសារមានយ៉ាងបរិបូណ៌ ប្រទេសយើងបានចាប់ថ្នាក់ជាប់ជាមួយប្រទេសទាំងឡាយដែលមានសាកលវិទ្យាល័យច្រើនជាងគេបំផុត (គឺសាកលវិទ្យាល័យមួយសំរាប់ប្រជាជនតិចជាងមួយលាននាក់)

ចំណែកឯព្រះវិធានការមួយទៀត ដែលបានកែប្រែមនុស្ស "ពីខ្មៅទៅស" នោះ គឺការបង្រៀនអក្សរដល់ជនានុជនដែលនៅមិនទាន់ចេះនៅឡើយ ។ កូនចៅព្រះអង្គគ្រប់សញ្ជាតិ គ្រាន់តែឮព្រះសូរសៀងនេះភ្លាម ក៏នាំគ្នាម្នីម្នាកន្ត្រាក់ក្ដារឈ្នួនចាប់ផ្ដើមភ្លាម ។ ឯកជននិងអង្គការសប្បុរសទាំងឡាយក៏បានសុំខ្លួនចូលរួមវិភាគទាន។ រីឯសមាគមយើងក៏នឹងបើកទ្វារបង្រៀនចាប់ពីថ្ងៃ១ធ្នូនេះតទៅហើយ ដូចមានសេចក្ដីជូនដំណឹងតាមវិទ្យុ

# ការរៀបចំឡើងវិញនិងការពង្រីក

គ្រាន់តែក្នុងរយៈពេល១០ឆ្នាំឯករាជ្យប៉ុណ្ណោះ ពលរដ្ឋខ្មែរ ក្រោមព្រះកិច្ចមគ្គុទ្ទេសដ៏ភ្លឺស្វាងនៃព្រះបិតាឯករាជ្យ-សាមគ្គីភាពជាតិ បានសំរេចជោគជ័យយ៉ាងសំបើមនៅក្នុងគ្រប់វិស័យ ក្នុងគ្រប់ខណ្ឌធ្វើឲ្យប្រទេសខ្មែររស់ដោយខ្លួនឯង ។ ទោះបីមហាអំណាចនិងអ្នកសារព័ត៌មានប៉ែកបស្ចិមខ្លះនៅតែមានះបទុះបង្អាប់សមិទ្ធិនិងវឌ្ឍនភាពរបស់ខ្មែរយើងក៏ដោយ ក៏សមិទ្ធិនិងវឌ្ឍនភាពរបស់យើងនៅតែបន្តដំណើរទៅមុខដដែល ។

កាលពីថ្ងៃ៩តុលា ១៩៦៤ គ្រាន់តែព្រះអង្គទ្រង់យាងនិវត្តន៍មកដល់មាតុភូមិភ្លាម សម្តេចព្រះបិតាសិក្សាធិការជាតិទ្រង់បានសព្វព្រះរាជហឫទ័យយាងមកជាព្រះរាជាធិបតីក្នុងការប្រជុំការងារមួយ ស្តីអំពីការរៀបចំឡើងវិញនិងការពង្រីកឧត្តមនិងវិជ្ជាជីវៈសិក្សាយើងសព្វថ្ងៃ ។

ការប្រជុំនេះ បានប្រព្រឹត្តទៅអស់រយៈពេល៣ម៉ោង នៅក្នុងព្រះបរមរាជវាំង ដោយមានឥស្សរជនជាន់ខ្ពស់ជាច្រើនបានចូលរួមផង ។

សេចក្តីសំរេចទាំងប៉ុន្មានដែលចេញមកអំពីការពិភាក្សានាថ្ងៃនោះ ប្រកបទៅដោយសារៈសំខាន់ខ្លាំងណាស់ ហើយអាចនឹងធ្វើឲ្យឧត្តមសិក្សារបស់យើង «លោក-

# ឧត្តមនឹងវិជ្ជាជីវៈសិក្សា

ផ្លោះ,, ទៅមុខបានយ៉ាងឆ្ងាយ ។

សាកលវិទ្យាល័យ ទាំងប៉ុន្មានដែលការប្រជុំបានសំរេចជានឹងបង្កើតមានដូចតទៅ៖

ក– រាជសាកលវិទ្យាល័យខ្មែរ **(U.R.K.)** ដែលមាន :

១. មហាវិទ្យាល័យនីតិវិទ្យា និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ;

២. មហាវិទ្យាល័យវេជ្ជវិទ្យា និងវិទ្យាសាស្ត្រ «paramédical» ;

៣. មហាវិទ្យាល័យអក្សរសាស្ត្រ និងវិទ្យាសាស្ត្រមនុស្សធម៌ ;

៤. មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកទេស ;

៥. មហាវិទ្យាល័យឱសថវិទ្យា ;

៦. មហាវិទ្យាល័យគរុកោសល្យ ដែលហ្វឹកហ្វឺនសាស្ត្រាចារ្យមធ្យមសិក្សា បឋមនិងមធ្យមភូមិ ។

ខ– រាជសាកលវិទ្យាល័យបច្ចេកទេសខ្មែរ**(U.T.R.K.)** ដែលមាន :

១ វិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់ មិត្តភាពខ្មែរ-សូវៀត ដែលមានមហាវិទ្យាល័យ៥ (សូមអានអត្ថបទ "វិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់ មិត្តភាពខ្មែរ–សូវៀត" តពីអត្ថបទនេះទៅ);

២. សាលាជាន់ខ្ពស់ខាងសិល្បៈនិងមុខរបរ (អតីតសាលាជាតិខាងសិល្បៈនិងមុខរបរ);

៣. សាលាជាន់ខ្ពស់ខាងគីមី(អតីតសាលាហ្វឹកហ្វឺនអ្នកជំនួយខាងគីមី) ដែលហ្វឹកហ្វឺនអ្នកជំនួយខាងគីមីនិងវិស្វករគីមី;

៤. សាលាជាន់ខ្ពស់ខាងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងពាណិជ្ជកម្ម (អតីតសាលាជាតិពាណិជ្ជកម្ម);

៥. សាលាជាន់ខ្ពស់ខាងសាធារណការ និងរ៉ែ (អតីតសាលាជាតិខាងសាធារណការ អគារនិងរ៉ែ) —ចំណែកឯការសិក្សាអំពីអាគារវិទ្យា (ផ្នែកស្ថាបត្យកម្ម និងត្រូវបញ្ចូលទៅក្នុងសាកលវិទ្យាល័យមួយទៀត ចាប់ពីពេលនេះតទៅ);

៦. សាលាជាន់ខ្ពស់ខាងអាកាសចរស៊ីវិល;

៧. សាលាជាន់ខ្ពស់ខាងនាវាចរពាណិជ្ជកម្ម (អតីតសាលាអ្នកបើកបរ) ។

គ– រាជសាកលវិទ្យាល័យខាងវិទ្យាសាស្ត្រក្សេត្រកម្ម (Université Royale des Sciences Agronomiques (**U.R.S.A.**) ដែលមាន :

១ មហាវិទ្យាល័យ វិទ្យាសាស្ត្រកសិកម្ម;

២. មហាវិទ្យាល័យ វិទ្យាសាស្ត្របសុវិទ្យា;

៣. មហាវិទ្យាល័យ វិទ្យាសាស្ត្ររុក្ខា;

៤. មហាវិទ្យាល័យ វិទ្យាសាស្ត្រមច្ឆវប្បកម្ម;

៥. មហាវិទ្យាល័យ ខាងជំនាញជនបទ ។

ឃ– រាជសាកលវិទ្យាល័យខាងវិចិត្រសិល្បៈដែលមាន

ការសិក្សាទាក់ទងទៅនឹងសាខាវិជ្ជាដូចតទៅ :

របាំ (របាំព្រះរាជទ្រព្យអឺរ៉ុប របាំប្រជាប្រិយ ។ល។..) តន្ត្រី សិល្បៈផ្លាស្ទិច បុរាណវត្ថុវិទ្យា ស្ថាបត្យកម្មនិងការលំអទីក្រុង ។

## ង_ ពុទ្ធិកសាកលវិទ្យាល័យ

ដែលមានសព្វថ្ងៃនេះ ។

## ច_ រាជសាកលវិទ្យាល័យ កំពង់ចាម ដែលមានៈ

១. មហាវិទ្យាល័យ យន្តវិទ្យា (mécanique) ;

២. មហាវិទ្យាល័យ ខាងវិទ្យាអំពីដំណាំក្នុងតំបន់ «tropical» ;

៣. មហាវិទ្យាល័យ វិទ្យាសាស្ត្ររូប-គណិត (physico-mathématiques) ។

សម្តេចទ្រង់សព្វព្រះរាជហឫទ័យនឹងយាងទៅជាព្រះរាជាធិបតីក្នុងពិធីដាក់បឋមសិលា ក្នុងខែធ្នូ ១៩៦៤ ។

សម្តេចទ្រង់បានសរសើរដល់ខេត្តកំពង់ចាម ដែលមានសេចក្តីសោមនស្សយ៉ាងសកម្ម ដោយសន្យាថានឹងស្ថាបនាអាគារ ១៨ ខ្នង សំរាប់សាកលវិទ្យាល័យនៃក្រុងរបស់ខ្លួន ។ អាគារម៉ាសរ៉ា ដែលនឹងស្ថាបនាឡើងដោយធនធានសពលោក ម៉ាសរ៉ា គឺជារង្គមណ្ឌល (amphithéâtre) នៃសាកលវិទ្យាល័យ ។ ខេត្តស្ទឹងត្រែងនឹងក្រចេះ អាចនឹងស្ថាបនាផ្ទះសំរាប់និស្សិតសំណាក់ផ្សេងពីគ្នាក៏បាន រួមជាមួយគ្នាក៏បាន ។ ឯខេត្តកំពង់ធំនឹងស្ថាបនាផ្ទះសំណាក់នេះដោយឡែកតែឯង ។

## ឆ_ រាជសាកលវិទ្យាល័យ តាកែវ-កំពត

រាជសាកលវិទ្យាល័យនេះ នឹងស្ថាបនាឡើងនៅលើមណ្ឌលសីមាខេត្តតាកែវ កំពត ត្រង់ភ្នំនរាយ (ផ្លូវភ្នំពេញ កំពត) ។ រាជសាកលវិទ្យាល័យនេះ ក៏ដូចជារាជសាកលវិទ្យាល័យកំពង់ចាមដែរ នឹងចេញជារូបរាងឡើងដោយលក្ខណៈដូចតទៅ : អាគារនឹងស្ថាបនាឡើងដោយពលរដ្ឋនៃខេត្តទាំងពីរ, រដ្ឋនឹងផ្តល់បុគ្គលិកដូន, គ្រឿងបរិក្ខារនឹងត្រូវផ្តល់ដោយព្រះប្រមុខរដ្ឋ ហើយមិនទ្រង់នាយករដ្ឋមន្ត្រី ។

ក្នុងជំហានដំបូង រាជសាកលវិទ្យាល័យនេះ នឹងបានទទួលផលទានមួយ

លានរៀលដែលសម្តេចទ្រង់នឹងសព្វព្រះរាជហឫទ័យយកទៅប្រទានក្នុងនាមនៃធនាគារជាតិ ។ ព្រះបិតាសិក្សាធិការទ្រង់នឹងយាងទៅជាព្រះរាជាធិបតីក្នុងពិធីដាក់បឋមសិលានៅខែមករា ១៩៦៤ ។

រាជសាកលវិទ្យាល័យនេះ មានជាអាទិ៍ :

១. មហាវិទ្យាល័យ អគ្គិសនីវិទ្យាមួយ,

២. មហាវិទ្យាល័យ វិទ្យាសាស្ត្រខាងសាគរវិទ្យា(océanographie) មួយ ។

លើសពីនេះទៅទៀត សាកលវិទ្យាល័យនឹងមានបច្ចេកសិក្សាទាំងអស់ដែលទាក់ទងទៅនឹងការប្រើប្រាស់ថាមពលនៃធនធានសមុទ្រ ។

## នាយកនៃរាជសាកលវិទ្យាល័យ

នាយកនៃសាកលវិទ្យាល័យទាំង៦ ដែលបានបង្គុលឈ្មោះហើយមានដូចតទៅ ៖

១. លោក គុង គុន បណ្ឌិតខាងច្បាប់និងសេដ្ឋកិច្ចនៃមហាបរិញ្ញាបត្រ (agrégatif) នៃមហាវិទ្យាល័យច្បាប់ នាយកនៃរាជសាកលវិទ្យាល័យ ភ្នំពេញ;

២. លោក ផុក ឆាត វិស្វករខ្មែរទី ១ ខាងស្ពាននិងថ្នល់ នាយកនៃរាជសាកលវិទ្យាល័យបច្ចេកទេស;

៣. លោក គាត ឈន វិស្វករខាងទេពកោសល្យសមុទ្រនិងខាងទេពកោសល្យបរមាណូ (Ingénieur du génie maritime et du génie atomique) នាយកនៃរាជសាកលវិទ្យាល័យ កំពង់ចាម;

៤. លោក វណ្ណ មូលីវណ្ណ ស្ថាបត្យករ (D.L.P.G.) ខ្មែរទី១ ចេញពីសាលាជាតិខាងវិចិត្រសិល្បៈ (ប្រទេសបារាំង)

នាយកនៃរាជសាកលវិទ្យាល័យ វិចិត្រសិល្បៈ;

៥. លោក គួ ស៊ីអ៊ុយ បណ្ឌិតភូមិទី ៣ (3e cycle) ខាងគីមី

នាយកនៃរាជសាកលវិទ្យាល័យ តាកែវ-កំពត;

៦. លោក ហូ តុងលិប វិស្វករក្សេត្រវិទ្យា នឹងសញ្ញាបត្រនៃសាលាជាន់ខ្ពស់ខាងការអនុវត្តនៃក្សេត្រវិទ្យាតំបន់"ត្រូពិកាល" (Application de l'Agronomie Tropicale)

នាយកនៃរាជសាកលវិទ្យាល័យ វិទ្យាសាស្ត្រក្សេត្រកម្ម ។

ចំណែកឯ

លោក ចៅ សេង បរិញ្ញាបត្រសិក្សាធិការខាងអក្សរសាស្ត្រ (licencié d'enseignement es lettres) នឹងសញ្ញាបត្រខាងចិត្តវិទ្យានឹងគរុកោសល្យវិទ្យា

នាយកនៃពុទ្ធិកសាកលវិទ្យាល័យ ។

3

*សូមមិត្តតំណាងសាលានិមួយៗ មេត្តាចាប់អារម្មណ៍ថា៖*

ប្រសិនបើមិត្តមិនផ្តល់ដំណឹងសុខទុក្ខនៃមិត្តយើងម្នាក់ៗ មកគណៈកម្មាធិការនាយកយើងផងទេ នោះគណៈកម្មាធិការនាយកគ្មានវិធីឯណានឹងដឹងសុខទុក្ខរបស់មិត្តយើងបានឡើយ ។

ដើម្បីធ្វើឱ្យ គ.ន.នៃស.ស.ខ យើង ជាប់ជិតស្និទ្ធនឹងមិត្តយើងទាំងអស់ សូមមិត្តតំណាងមេត្តាបំពេញភារៈនេះឱ្យបានដិតដល់ ។

# វិទ្យាស្ថាន បច្ចេកទេស ជាន់ខ្ពស់

មិ

ខ្មែ

វិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាពខ្មែរ-សូវៀតនេះ សហភាពសូវៀតបានស្ថាបនាឡើង ជាអំណោយដល់រាជរដ្ឋាភិបាលនិងប្រជាពលរដ្ឋខ្មែរ ។ វិទ្យាស្ថាននេះជាជាតិអាគារសិក្សាបច្ចេកទេសជាន់ខ្ពស់ ដែលមានភារៈនឹងអប់រំបង្កើតវិស្វករជំនាញសំរាប់ឧស្សាហកម្ម សំរាប់ការស្ថាបនានិងកសិកម្មនៃព្រះរាជាណាចក្រ ។

ការបង្កើតវិទ្យាស្ថាននេះជាបាតុភាពមួយយ៉ាងច្បាស់ក្រឡែតបង្ហាញឲ្យឃើញថា សម្តេចឪព្រះប្រមុខរដ្ឋនិងរាជរដ្ឋាភិបាល បានយកព្រះហឫទ័យនិងយកចិត្តទុកដាក់យ៉ាងក្រៃលែងចំពោះការពង្រីកសេដ្ឋកិច្ចជាតិ ចំពោះការសិក្សានិងចំពោះការលើកស្ទួយឋានៈវប្បធម៌នៃពលរដ្ឋ ។ ហើយនេះក៏ជាសក្ខីភាពបង្ហាញយ៉ាងជាក់ស្តែងនូវមិត្តភាពដែលកាន់តែរីកធាត់ធំឡើងៗនិងសហប្រតិបត្តិការប្រកបទៅដោយផ្លែផ្កា រវាងប្រទេសកម្ពុជានិងសហភាពសូវៀតដែរ ។

នៅក្នុងវិទ្យាស្ថាន គេសង្កេតឃើញសាលសន្និសីទដ៏ធំទូលាយនិងសាលទូលាយៗសំរាប់ការសិក្សាប្រតិបត្តិ( l'étude pratique) សំរាប់គន្លូបច្ចេកទេសនិងគំរោងការ សាលពិសោធនិងរោងជាងឯកទេស ព្រមទាំងវេទិកា( la chaire )សំខាន់ៗចំនួន២៦ទៀតផង ។

សាលពិសោធ ពេនជាងនឹងសាលសិក្សាទាំងអស់សុទ្ធតែប្រកបដោយបរិក្ខារយ៉ាងទំនើបបំផុត ជាហេតុដែលធ្វើឲ្យនិស្សិតអាចសិក្សាបានចេះយ៉ាងឆាប់រហ័សនិងយ៉ាងងាយ នៅលើមូលដ្ឋាននៃវឌ្ឍនភាពវិទ្យាសាស្ត្រនឹងបច្ចេកទេសក្នុងសម័យបច្ចុប្បន្ន ។

# ក្ដ ភា ៣
# ទ- ស្ទទៀត

លើសពីនេះទៅទៀត វិទ្យាស្ថានមានសាលសំរាប់បណ្ណាល័យ ហើយនិងមហាសាលមួយសំរាប់ធ្វើសន្និបាត ធ្វើពិធីសមោសរ ឬការកំសាន្តផ្សេងៗ ។ល។ ចំណែកឯទីធ្លាកីឡាក៏មានដែរ ។

## ◙ សាខានៃវិជ្ជា

មហាវិទ្យាល័យទាំងប្រាំនៃវិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់គឺ:

--មហាវិទ្យាល័យស្ថាបត្យកម្ម នឹងស្ថាបនកម្ម

--មហាវិទ្យាល័យផលវិទ្យាកសិកម្ម

--មហាវិទ្យាល័យអគ្គិសនីបច្ចេកទេស នឹង

--មហាវិទ្យាល័យភាយនកណ្ឌ ។

មហាវិទ្យាល័យទាំងនេះរ៉ាប់រងហ្វឹកហ្វឺននិស្សិតជំនាញដែលមានសារៈសំខាន់បំផុតសំរាប់សេដ្ឋកិច្ចជាតិ ។ រយៈពេលសិក្សានៅក្នុងគ្រប់មហាវិទ្យាល័យគឺ ៤ ឆ្នាំ ១០ ខែ ។

## មហាវិទ្យាល័យស្ថាបត្យកម្មនឹងស្ថាបនកម្ម

ទទួលហ្វឹកហ្វឺននិស្សិតស្ថាបត្យករ សំរាប់ធ្វើគំរោងការសំណង់អាគារលំនៅនឹងសំណង់ផ្សេងៗទៀត ។ ក្នុងមួយឆ្នាំ មហាវិទ្យាល័យជ្រើសរើសនិស្សិតចំនួន ១៥០ នាក់ ។

### មហាវិទ្យាល័យជលវិទ្យាកសិកម្ម

ទទួលហ្វឹកហ្វឺនវិស្វករ-ជលបច្ចេកទេសសំរាប់ធ្វើគំរោងការខាងសំណង់និងខាងអាជីវកម្មនៃជលបថនកណ្ឌ( l'installation hydraulique )និងរបៀបប្រើប្រាស់ទឹកសំរាប់កសិកម្ម ។ ក្នុងមួយឆ្នាំ មហាវិទ្យាល័យជ្រើសរើសនិស្សិតចំនួន ៥០ នាក់ ។

### មហាវិទ្យាល័យរ៉ែ

ទទួលហ្វឹកហ្វឺនវិស្វករខាងរ៉ែ ដើម្បីនឹង: ១) «ស្រាវជ្រាវរុករកផែនរ៉ែក្រោមដី» ២) «ប្រើប្រាស់ផែនរ៉ែ» ។ ចំនួននិស្សិតជ្រើសរើសក្នុងមួយឆ្នាំគឺ ៥០ នាក់ ។

### មហាវិទ្យាល័យអគ្គិសនីបច្ចេកទេស

ទទួលហ្វឹកហ្វឺនវិស្វករអគ្គិសនីសំរាប់ធ្វើគំរោងការផ្តល់អគ្គិសនីដល់សហគ្រាសឧស្សាហកម្មនិងដល់ទីក្រុង សំរាប់តម្លើងនិងធ្វើអាជីវកម្មកម្លាំងអគ្គិសនី ។

### មហាវិទ្យាល័យវាយនភណ្ឌ

ទទួលហ្វឹកហ្វឺនវិស្វករបច្ចេកវិទ្យា (ingénieur technologique) ខាងបញ្ហាបច្ចេកវិទ្យាគីមីនិងយន្តសាស្ត្រនៃផលិតកម្មសំពត់អំបោះ ។ ក្នុងមួយឆ្នាំ មហាវិទ្យាល័យជ្រើសរើសនិស្សិត ២៥ នាក់ ។

## ▣ ក្រឡេកមើលការសិក្សានៅវិទ្យាស្ថាន

ការសិក្សានៅវិទ្យាស្ថានធ្វើឡើងនៅលើមូលដ្ឋាននៃវិទ្យាសាស្ត្រនិងបច្ចេកទេសទំនើប ។ វិទ្យាស្ថាននេះជាមណ្ឌលនៃការពង្រីកគំនិតជាតិខាងបច្ចេកទេស ។ ការសិក្សាមានគោលបំណងនឹងពង្រីកនូវគំនិតប្រឌិត(l'esprit d'initiatives )និងគំនិតឯករាជរបស់និស្សិតក្នុងការដោះស្រាយបញ្ហាវិទ្យាសាស្ត្រនិងបច្ចេកទេសទាំងឡាយ ហើយ

មានគោលបំណងនឹងជួយសំរួលនិស្សិតទាំងនេះនៅក្នុងវិធីចំរើននៃការងារធ្វើគ្រោងការទៅតាមវិជ្ជាឯកទេស ។

ក្រៅពីពេលរៀនក្នុងថ្នាក់ ផែនការសិក្សាបានគ្រោងទុកនូវការសិក្សាយ៉ាងទូលំទូលាយផ្សេងៗទៀត នៅក្នុងសាលពិសោធ ហើយនឹងការងារធ្វើគំរោងការតាំងឡាយ ដែលនឹងជួយសិស្សឲ្យយល់នូវបញ្ហាបច្ចេកទេសខាងការស្រាវជ្រាវនឹងការដោះស្រាយបញ្ហាជាក់ស្តែងនៅក្នុងជីវភាពរបស់គេ ។

បន្ទាប់ពីសិក្សាធម្មតាមក និស្សិតនឹងត្រូវបំពេញកម្មសិក្សាប្រតិបត្តិ ( le stage pratique ) ទៀត ដែលមានគោលបំណងនឹងពង្រីកនូវវិជ្ជាដែលខ្លួនបានរៀនចេះហើយ ហើយនឹងទំលាប់សិស្សឲ្យស្គាល់លក្ខណៈពិសេសៗនៃការងាររបស់ខ្លួននាពេលអនាគត ។

ក្រៅពីការសិក្សាជាកាតព្វកិច្ច និស្សិតអាចនឹងជ្រើសរើសនូវមុខវិជ្ជាបន្ថែមខ្លះទៀតដែលខ្លួនអាចនឹងមិនយកក៏បាន យកក៏បានទៅតាមផលប្រយោជន៍នឹងសម្បត្តិផ្ទាល់របស់ខ្លួន ។

នៅវិទ្យាស្ថាន គេក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការហាត់ប្រាណនឹងកីឡា ដើម្បីឲ្យរាងកាយនិស្សិតលូតលាស់ទៅបានយ៉ាងសមរម្យ ហើយដើម្បីនឹងពង្រីកនូវសមត្ថភាពកីឡារបស់គេផង ។

---

នៅចុងឆមាសនិមួយៗ និស្សិតត្រូវធ្វើការប្រឡង ដែលមានគ្រោងទុកក្នុងគំរោងសិក្សា ។ នៅឆ្នាំចុងក្រោយបំផុតនៃការសិក្សារបស់ខ្លួន និស្សិតនឹងធ្វើវិក្រឹតការនៅក្នុងមុខវិជ្ជាពិសេសរបស់ខ្លួន ហើយធ្វើនិក្ខេបបទមួយអំពីមុខវិជ្ជាពិសេសដែលខ្លួនបានជ្រើសរើស ។ និក្ខេបបទនេះនឹងធ្វើឡើងចំពោះមុខគណៈកម្មការរដ្ឋ ដែលមានសាស្ត្រាចារ្យមានសមត្ថកិច្ច ហើយនឹងអ្នកតំណាងមន្ទីររដ្ឋមន្ត្រីអប់រំជាតិ ។

★




## PROGRAMME D'ETUDES de L'INP

La commission mixte chargée de modifier le programme d'études de l'Institut National Pédagogique(formation des professeurs de l'Enseignement Secondaire du Premier Cycle), après une longue discussion et échange de vue, a adopté à l'unanimité (pour la 2è année de Formation) à savoir:

### I- le sytème d'horaires suivant;

| disciplinesoptées | | matières annexes | matières secondaires | | | | | stage (1) |
|---|---|---|---|---|---|---|---|---|
| | | | Langue et Civ | Cult. Géner | Psych | Pédag | Ad. Scol | |
| M.P.C. | M:8h+(2h de Méth)C<br>P: 5h+(2h — ) | 2h | L.K. 1h | 2h | 2h | 2h | 1h | |
| P.C.MG. | P: 6h+(2h de Méth)MG<br>C: 5h+(2h — ) | 4h | L.K. 1h | 2h | 2h | 2h | 1h | |
| Sn.C.P. | Sn:7h+(2h de Mét )P<br>C: 5h+(2h — ) | 3h | L.K. 1h | 2h | 2h | 2h | 1h | |
| Fr. Angl. | Fr: 10h+(2h Méth)<br>Angl: 5h+(1h — ) | | L.K. 1h<br>C.K. 1h | 2h | 2h | 2h | 1h | |
| Angl. Fr. | Angl: 10h+(2hMét)<br>Fr: 5h+(1h — ) | | L.K. 1h<br>C.K. 1h | 2g | 2h | 2h | 1h | |
| Hist.Géo. | Hist: 8h+(2h Méth)<br>Géo: 7h+(1h — ) | | L.K. 1h<br>C.K. 1h | 2h | 2h | 2h | 1h | |
| Kh.Pal.fr | Kh: 8h+(2h Méth)<br>Pal: 6h+(1h — ) | | E.K. 1h | 2h | 2h | 2h | 1h | |

(1) Le stage se fera en deux périodes de 15 jours dans les classes secondaires annexées à l'Institut National Pédagogique et dans celles des Lycées de la Capitale.

## 2- Les conditions d'admission suivantes:

1. Les instituteurs du D.C. (3 ans de service) et les élèves titulaires de la 1ère partie du Bac. (Section Générale) auront à subir les épreuves comme indique le tableau ci-après:

| matiere optees | coef | culture general en cambodgien | coef |
|---|---|---|---|
| MG. + P. | 3+2 | -id- | 1 |
| P. + C. | -id- | -id- | 1 |
| Sn. + C. | -id- | -id- | 1 |
| Fr. + Angl. | -id- | -id- | 1 |
| Angl. + Fr. | -id- | -id- | 1 |
| Hist. + Géo. | -id- | -id- | 1 |
| Khm. + Fr. | -id- | -id- | 1 |

2. Les intituteurs du C. D. et les normaliens titulaires de la 1ère partie du Bac. seront admis d'office.

3. Les titulaires du Bac. complet, désormais, auront à subir un test facile en langue khmère et les admis devront choisir leurs options en conformité avec la nature de leur diplôme et avec leurs aptitudes.

N. B. :- Le système de groupes en 2è année sera supprimé à partir de l'année scolaire 1664-65.

## 3- Le système d'examen de sortie suivant:

| SECTIONS | epreuves (1) | | | compos. (2) | |
|---|---|---|---|---|---|
| | ECRITES | ORALES | CLASSE PRATIQUE | 1èr An. | 2è An. |
| MG.P.C. | MG. Coef. 3<br>P. -id- 2<br>C. -id- 1<br>Psy. Péd. 1 | MG. Coef. 3<br>P. -id- 2 | MG. Coef. 2<br>P. -id- 2 | | |
| P.C.MG. | P. Coef. 3<br>C. -id- 2<br>MG. -id- 1<br>Psy. Péd. 1 | P. Coef. 3<br>C. -id- 2 | P. Coef. 2<br>C. -id- 2 | | |
| Sn.C.P. | Sn. Coef. 3<br>C. -id- 2<br>P. -id- 1<br>Psy. Péd. 1 | Sn. Coef. 3<br>C. -id- 2 | Sn. Coef. 2<br>C. -id- 2 | | |
| Fr. Angl. | Fr. Coef. 3<br>Angl. -id- 2<br>Kh. -id- 1<br>Psy. Péd. 1 | Fr. Coef 3<br>Angl. -id- 2 | Fr. Coef. 2<br>Angl. -id- 2 | | |
| Angl. Fr. | Ang. Coef. 3<br>Fr. -id- 2<br>Kh. -id- 1<br>Psy. Péd. 1 | Angl. Coef. 3<br>Fr. -id- 2 | Angl. Coef. 2<br>Fr. -id- 2 | | |
| Hist. Géo. | Hist. Coef. 3<br>Géo -id- 2<br>Kh. -id- 1<br>Psy. Péd. 1 | Hist. Coef. 3<br>Géo. -id- 2 | Hist. Coef. 2<br>Géo. -id- 2 | | |
| Kh. Pali | Kh. Coef. 3<br>Pal. -id- 2<br>Fr. -id- 1<br>Psy. Péd. 1 | Kh. Coef. 3<br>Pal. -id- 2 | Kh. Coef. 2<br>Pal. -id- 2 | | |

(1) Les notes de l'examen sont sur 30. La note zéro dans n'importe quelle épreuve est éliminatoire.

(2) Les notes de compositions sont:
— sur 10 (1ère Année)
— sur 20 (2ème Année)

# ការអប់រំ ជាចន្លុះនៃប្រជាជាតិ



កុមារទាំងពីរនាក់ នឹងសិក្សាសៀវភៅទាំងនេះដែលមានកំពស់ស្មើនឹងធំហររបស់គេ ក្នុងរយៈ៩ឆ្នាំនៃការសិក្សាកាតព្វកិច្ច ។

ប្រជាជនជប៉ុន បានសំរេចសេចក្ដីចំរើនមួយគួរឲ្យស្ញប់ស្ញែងក្នុងវិស័យនៃការសិក្សា ។ សេចក្ដីសប្បាយរីករាយរបស់មាតាបិតាសិស្ស របស់សាស្ត្រាចារ្យនិងគ្រូបង្រៀនរបស់រដ្ឋាភិបាលជាតិនិងរដ្ឋាភិបាលតំបន់ ហើយជាអាទិគីរបស់ក្មេងទាំងឡាយ បានធ្វើឲ្យប្រទេសជប៉ុនអាចឈានទៅដល់កំរិតយ៉ាងខ្ពស់នៃរបបសិក្សា (le système d'enseignement) របស់ខ្លួនៗ ប្រទេសជប៉ុនជាប្រទេសទី១ក្នុងទ្វីបអាស៊ី ហើយទី៣ក្នុងពិភពលោកដែលបានសំរេចយករបបសិក្សាជាកាតព្វកិច្ច ៩ ឆ្នាំ (le système de 9 ans d'enseignement obligatoire) មកអនុវត្ត ។ តាមរបបនេះកុមារជប៉ុនដែលមានអាយុពី៦ទៅ ១៥ ឆ្នាំសុទ្ធតែត្រូវបានទទួលបឋមវិជ្ជា ៦ ឆ្នាំ និងមធ្យមវិជ្ជា ៣ ឆ្នាំ គ្រប់ៗរូប ។ ស្ថិតិដែលមានមកហើយ បានបង្ហាញយ៉ាងច្បាស់ថា តើការសិក្សាបានជ្រាបចូលទៅក្នុងកល់ស្រទាប់សង្គមប៉ុណ្ណោះហើយ ។ ដូចជាសព្វថ្ងៃនេះ ប្រជាជនជប៉ុនមិនបេះ

# កំពុងលូតលាស់

អក្សរមានចំនួនត្រឹមតែ១,៦ ភាគរយតែប៉ុណ្ណោះ ។ តាមចំនួននៃការកត់ត្រាសព្វថ្ងៃនេះ មានក្មេងអាយុពី ៦ ទៅ ១២ ឆ្នាំ ចំនួន ៩៩,៩ ភាគរយ បានចុះឈ្មោះចូលសាលាបឋមសិក្សា ហើយមានយុវជនអាយុពី១៣ទៅ១៥ឆ្នាំចំនួន៩៩,៨ភាគរយ បានចុះឈ្មោះចូលសាលាមធ្យមសិក្សា ។ ទាំងអស់មានសាលាបឋមសិក្សាចំនួន ២៦.៩៦៤ខ្នង សាលាមធ្យមសិក្សា ១២.៦៤៧ខ្នង ដែលនៅទីនោះមានសិស្សានុសិស្សនិងនិស្សិតចំនួន ១៩ លាននាក់ ហើយនិងគ្រូបង្រៀននិងសាស្ត្រាចារ្យសំរាប់ការសិក្សាកាតព្វកិច្ចចំនួន ៥៩០.០០០ នាក់ ។

គំនិតដែលបង្កើតការសិក្សាសាធារណៈមានបិតនៅក្នុងប្រទេសជប៉ុនតាំងពីយូរយារមុនយុគដើមនៃប្រទេសជប៉ុនសម័យថ្មីទៅទៀត; យុគដើមនេះមានការបង្កើតសកពជម៊ីយី (Ere de Meiji) ក្នុងឆ្នាំ១៨៦៨ជាសំគាល់ ។ កាលពីមុនកាលបរិច្ឆេទនេះ របបសិក្សាបិតនៅលើសាលាវត្ត (Terakoya) សំរាប់កូនពួកម្ចាស់ដីនិងកូននៃវណ្ណៈពាណិជ្ជករ ហើយបិតនៅលើសាលាបក្ខសម្ពន្ធ ( Hanko ) កាតព្វកិច្ចពាក់កណ្ដាលសំរាប់កូនអ្នកចំបាំង ។ របបសិក្សាកាតព្វកិច្ចសម័យថ្មី ដែលបិតនៅលើស្ថាប័នខាងលើនេះបានកើតឡើងក្នុងឆ្នាំ១៨៧២ ក្នុងសម័យដែលប្រទេសជាតិបានបើកទ្វារទទួលអារ្យធម៌អឺរ៉ុប ។

របបនេះកាន់តែបានលំអឡើង ៗ ហើយរីកលូតលាស់ឡើង ៗ យ៉ាងទៀងទាត់

ហើយរហូតមកទល់នឹងមុនសង្គ្រាមលោកទី ២ មានប្រជាជនជប៉ុន ៩៥ ចំនួនភាគរយ បានចេះដឹង (instruit) ។ ក្រោយពីសម័យអមិត្តភាព (l'hostilité) មក របបអប់រំក៏បានកែទម្រង់ថែមទៀត ហើយថេរៈវេលាសិក្សាកាតព្វកិច្ចក៏បានបង្កើនពី ៦ ទៅ ៩ ឆ្នាំ ។ របបសិក្សាដែលអនុវត្តក្នុងសម័យបច្ចុប្បន្ននេះ មានឈ្មោះថា «របប ៦-៣-៣-៤» គឺថា :

- បឋមសិក្សាកាតព្វកិច្ច ៦ ឆ្នាំ
- មធ្យមសិក្សាកាតព្វកិច្ច ៣ ឆ្នាំ
- ឧត្តមសិក្សា ៣ ឆ្នាំ ហើយនឹង
- សាកលសិក្សា ៤ ឆ្នាំ (enseignement universitaire)

គេអាចនឹងចាត់ទុកថា របបសិក្សានៅប្រទេសជប៉ុន ជារបបមួយប្រសើរជាងគេបំផុត ក្នុងបណ្តារបបសិក្សាប្រសើរជាងគេបំផុតទាំងឡាយក្នុងពិភពលោក ។ នៅក្នុងប្រទេសទាំងមូល នៅក្នុងពល់ទីក្រុងហើយរហូតទៅដល់ភូមិឆ្ងាយៗដាច់ស្រយាលទៀតផង សាលារៀនបានបង្កើតជាភាពអំនួតនៃសហគម ដែលបញ្ជាក់នូវកំរិតអប់រំយ៉ាងខ្ពស់របស់ប្រជាជនជប៉ុនក្នុងសម័យបច្ចុប្បន្ន ហើយនឹងសេចក្តីស្រេកឃ្លានគ្មានឈប់ឈរនៃប្រជាជនជប៉ុនក្នុងការចង់ចេះដឹង ។

សកម្មភាពពល់ថ្ងៃនៅក្នុងសាលារៀន បង្ហាញនូវសារៈសំខាន់នឹងទំហំនៃកម្មវិធីសិក្សា ហើយនឹងបង្ហាញនូវការទាក់ទង ដែលកម្មវិធីនេះ មានជាមួយនឹងការរីកលូតលាស់នៃប្រជាជាតិ ។ សាលាទាំងឡាយមានបន្ទប់ប្រកបទៅដោយគ្រឿងប្រដាប់ល្អប្រពៃ មានកន្លែងហាត់ប្រាណមួយ (le gymnase) មានសាលពិសោធន៍មួយ ឬច្រើន ហើយនឹងសាលផ្សេងៗទៀត សំរាប់ថ្នាក់រៀនពិសេស (les cours spéciaux) ។ កម្មវត្ថុសិក្សាមានយ៉ាងច្រើនហើយទូលំទូលាយ រីឯវិធីសិក្សាដែលបានយកមកប្រតិបត្តិក៏មានច្រើនបែបបទណាស់ដែរ ។

សព្វថ្ងៃនេះ គេបានឲ្យសារៈសំខាន់ទៅគណិតសាស្ត្រនិងវិទ្យាសាស្ត្រ ក៏ដូចជាទៅសិល្បៈនិងអាជីពដែរដើម្បីនឹងឈមមុខឆ្ពោះទៅរកការចាំបាច់នៃលោកសម័យ ។ ការសិក្សាភាសាបរទេសចាប់ផ្ដើមនៅឆ្នាំទី១នៃសាលាមធ្យមសិក្សា ប្រយោជន៍ឲ្យស្មារតីក្មេងខ្ចីនៃកុមារបើកទ្វារទៅរកវប្បធម៌ដទៃឯទៀតៗក្នុងលោក ហើយប្រយោជន៍ឲ្យវាមានពិសោធន៍ផង ។

ប្រសិនបើគេបានទៅទស្សនាសាលាណាមួយ ទោះជាទៅដោយឥតបានប្រាប់ឲ្យសាលានោះប្រុងប្រៀបជាមុនក្ដី នោះគេនឹងយល់ភ្លាមថា ក្មេងៗជប៉ុនសប្បាយចិត្តនឹងទៅរៀនណាស់ ។ នៅឯណោះ គេឃើញសិស្សខ្លះចំរុះគ្នាផ្គុំមើលទូរទស្សន៍ដែលបញ្ចាំងនូវកម្មវិធីអប់រំ ។ នៅឯណោះ គេឃើញក្មេងៗរៀនលេងឧបករណ៍តន្ត្រីផ្សេងៗ ឬកំពុងតែស្ដាប់ដោយស្ងើចសរសើរនូវតន្ត្រីដ៏ល្បីល្បាញទាំងឡាយក្នុងលោក ដែលគេបានថតមកចាក់ពីរ៉េះដូចដើម (à haute fidélité) ។ មានបន្ទប់ខ្លះទទេយ៉ែត; នេះគឺមកពីសិស្សនិងគ្រូបាននាំគ្នាចេញធ្វើដំណើរកំសាន្ត ឬក៏ចេញទៅទស្សនាសារមន្ទីរ ឬបណ្ណាល័យណាមួយក្នុងតំបន់នោះបាត់ទៅហើយ ។ យុវជនអាយុតិចជាងម្ភៃឆ្នាំរៀនអំពីផ្នែកម៉ាស៊ីន (les éléments de mécanique) ដោយធ្វើការជាមួយនឹងម៉ាស៊ីនមែនទែន ចំណែកឯយុវនារីវិញរៀនដេរអាវនៅក្នុងសាលមួយផ្សេងទៀត ។

នៅប្រទេសជប៉ុន សកម្មភាពសិស្សមិនមែនកំណត់ត្រឹមតែក្នុងបន្ទប់រៀនប៉ុណ្ណោះទេ ។ សព្វថ្ងៃនេះ សកម្មភាពក្រៅបន្ទប់រៀនកាន់តែបានកើនឡើងៗខ្លាំងហើយ ៗ សិស្សានុសិស្សក៏ដូចជាគ្រូ ហើយជួនកាលមានទាំងមាតាបិតាសិស្សផងបានចូលរួមប្រស្រ័យក្នុងការសំរេចកម្មវិធីក្រៅបន្ទប់រៀននេះ ។ នៅក្នុងសាលារៀនជាច្រើន

សិស្សានុសិស្ស បាននាំគ្នាបង្កើតមណ្ឌលស្រាវជ្រាវដែលមានលក្ខណៈពិសេសៗ ដូចជាមណ្ឌលវិទ្យាសាស្ត្រ (le cercle d'intérêts scientifiques) មណ្ឌលកីឡាជាដើម ។ នៅជានីតូក្យូ មានសាលាបឋមសិក្សាមួយនោះមានតាំងក្រុមតន្ត្រីប្រគុំដោយគ្រឿងចំរុះរបស់ខ្លួនផង (l'orchestre symphonique) ។ បើនិយាយពីសាលាដែលមានក្រុមភ្លេងត្រែ (le fanfare) វិញនោះមានចំនួនច្រើនណាស់ ។

ដំណើរអប់រំ (les excursions éducatives) ដែលមានរយៈពេលពី២ទៅ៣ថ្ងៃ បានចូលជាចំណែកនៃកម្មវិធីសិក្សាប្រចាំឆ្នាំ ៗ ដំណើរអប់រំនេះ មានគោលបំណងនឹងជួយសិស្សឲ្យបានយល់ នឹងបានឃើញនៅនឹងកន្លែងតែម្តងនូវវត្ថុជាច្រើនដែលខ្លួនធ្លាប់បានរៀននៅក្នុងថ្នាក់រួចមកហើយ ។ ការអង្កេតបានបង្ហាញឲ្យឃើញថា កាលពីឆ្នាំទៅនេះ (១៩៦២) មានសាលាបឋមសិក្សា ៧៧ ភាគរយ នឹងសាលាមធ្យមសិក្សា ៨៨ ភាគរយបានធ្វើដំណើរអប់រំនេះ ។ សិស្សានុសិស្សតែងតែនាំគ្នាចង់ចាំស-ស្រាញ់នូវដំណើរអប់រំនេះ ដែលនឹងបានបិតនៅជាអនុស្សាវរីយ៍មិនអាចភ្លេចបាននៅក្នុងជីវភាពសិក្សារបស់ខ្លួន ។

គេអាចនឹងសង្កេតឃើញសំបូរណភាពខាងសេដ្ឋកិច្ចនៃប្រទេសជប៉ុនសព្វថ្ងៃនេះ នៅក្នុងការកែលូតលាស់ថ្មីៗនៃពន៍កាយរបស់យុវជន ។ បើនិយាយពីទំងន់នឹងមាឌ ទំងន់នឹងមាឌនៃយុវជនជំនាន់ក្រោយនេះ បានលូតលាស់ផុតទំងន់នឹងមាឌយ៉ាងខ្ពស់បំផុតនៃមនុស្សជំនាន់មុនសង្គ្រាមឆ្ងាយណាស់ ។ ជាឧទាហរណ៍ គឺមាឌមធ្យមនៃយុវជនជប៉ុនអាយុ ១១ ឆ្នាំ សព្វថ្ងៃ បានកើតឡើងបីសង់ទីម៉ែត្រ បើគិតត្រឹមតែ ១០ ឆ្នាំកន្លងទៅនេះ ។

នៅក្នុងគ្រួសារ មាតាបិតាជប៉ុនបានលៃពេលវេលានឹងកម្លាំងយ៉ាងច្រើនទុកសំរាប់អប់រំកូនរបស់ខ្លួន ។

ឯចំណាយសំរាប់ការអប់រំក៏តែងតែបានជាភាគមួយយ៉ាងធំនៃថវិកាគ្រួសារជាដរាប ។ តាមធម្មតា មាតាបិតាជប៉ុន ដែលជាអ្នកនិយមការអប់រំយ៉ាងលើសលុប តែងតែបានទុកការងាររបស់ខ្លួនមួយប៉ែកសិន ដើម្បីនឹងមកចូលរួមក្នុងសកម្មភាពនៃ សមាគមមាតាបិតានិងគ្រូបង្រៀន ដែលបានតាំងឡើងពាសពេញប្រទេស ។ ដោយហេតុតែកម្មវិធីសិក្សាបានទទួលការសើរើនឹងការពង្រីកជារឿយៗដើម្បីនឹងដើរឲ្យទាន់កាលៈទេសៈនោះ មាតាបិតាមានការលំបាកនឹងធ្វើខ្លួនឲ្យលូតលាស់ទាន់កូនរបស់ខ្លួនខ្លាំងណាស់ ។ ដូចនេះហើយបានជាជួនកាល សម័យប្រជុំនៃ «សមាគមមាតាបិតានិងគ្រូបង្រៀន» បានក្លាយទៅជាថ្នាក់រៀនសំរាប់មាតាបិតាទាំងនេះ ដែលបានចូលចិត្តនឹងជក់ចិត្តយ៉ាងខ្លាំង ។

ចំណែករដ្ឋាភិបាលវិញ ជារៀងរាល់ឆ្នាំ បានបោះផ្សាយ «សៀវភៅស» មួយស្ដីអំពីការអប់រំដើម្បីនឹងជួយប្រជាជន ឬ បើនិយាយឲ្យច្បាស់ទៅទៀតគឺជួយមាតាបិតាឲ្យយល់សភាពការណ៍សិក្សាបច្ចុប្បន្នកាន់តែបានច្បាស់ថែមទៀត ហើយនឹងជួយមាតាបិតានេះ នឹងបុត្ររបស់ខ្លួនក្នុងការជ្រើសរើសសាលាសិក្សា (le choix des études) ។ ចំណោះវិជ្ជាដែលបានសិក្សាហើយ សុទ្ធតែបានធ្វើការសាកល្បងមើលឡើងវិញ ទូទាំងប្រទេសក្នុងសាលាបឋមសិក្សា នឹង មធ្យមសិក្សា ។ ការសាកល្បង (les tests) នេះជួយរដ្ឋការតំបន់ឲ្យរក្សាកំរិតសិក្សានៅដដែល ហើយនឹងធ្វើការសិក្សាឲ្យកាន់តែប្រសើរឡើងទៀត ។ យើងសូមបញ្ជាក់ថា ចំណាយខាងការអប់រំបានជាចំណែកមួយយ៉ាងសំខាន់នៃថវិកាជាតិជប៉ុន ។ ចំណាយទាំងនេះ ចាយទៅលើការលំអកន្លែងនឹងការជ្រើសរើសហើយនឹងការពិនិត្យនឹងប្រាប់ឈ្មោះសៀវភៅសិក្សាដល់រដ្ឋការតំបន់ ។

ការគាំទ្រយ៉ាងម៉ឺងម៉ាត់នឹងការយកចិត្តទុកដាក់យ៉ាងជិតដល់នៃពល់ស្រទាប់សង្គមចំពោះវិសិដ្ឋការនៃការអប់រំបានធ្វើឲ្យប្រជាជាតិជប៉ុនមានរបបសិក្សាមួយស្របទៅតាមបែប

បទនៃជីវភាពសម័យនៃប្រទេសជប៉ុនដែលមានលក្ខណៈយ៉ាងស្មុគស្មាញ ហើយដែលផ្លាស់ប្តូរយ៉ាងរហ័សផង ។

## ការបង្រៀនតាមទូរទស្សន៍ នៅប្រទេសជប៉ុន

ចាប់តាំងពីខែមេសាមក នៅប្រទេសជប៉ុនគេបានចាប់ផ្សាយការបង្រៀនតាមទូរទស្សន៍សំរាប់ក្មេងដែលមានប្រាជ្ញាយឺត (mentalement retardé) ហើយដែលមានអាយុហួសបឋមវិជ្ជាទៅហើយ ។

កម្មវិធីនេះ ឆ្លើយតបទៅនឹងសេចក្តីត្រូវការដែលកាន់តែខ្លាំងឡើងៗក្នុងវិស័យការអប់រំ ។ តាមការអង្កេតដែលមន្ទីរអប់រំជប៉ុនបានធ្វើ គេឃើញថាក្នុងឆ្នាំ១៩៦៣ ប្រទេសនេះមានក្មេងប្រាជ្ញាយឺតចំនួន៧៨៨.៤០០នាក់ អាយុពី ៦ ទៅដល់ ១៥ ឆ្នាំ ។ ស្ថិតិបានបង្ហាញថា មានក្មេងបែបនេះចំនួនតែ ៧,៥៤%ទេ ដែលបានសិក្សាតាមការបង្រៀនខាងលើនេះ ។ ប៉ុន្តែក្នុង១០ឆ្នាំ ទៅមុខទៀត ការបង្រៀនតាមទូរទស្សន៍នឹងត្រូវបើកទៅដល់១ពាន់ថ្នាក់ ។

ចាប់ពីចុងឆ្នាំ ១៩៦២មក ការបង្រៀនពិសោធន៍តាមទូរទស្សន៍ «les cours expérimentaux télévisés» បានផ្សាយនៅប្រទេសជប៉ុន ដោយមានការឧបត្ថម្ភពីអ្នកអប់រំ ពីគ្រូពេទ្យនឹងពីចិត្តវិទូ ។ គេបានយកលទ្ធផលនៃការបង្រៀនល្បងនេះ ក្នុងមួយរយថ្នាក់ដែលនៅក្នុងកដ្ឋានផ្សេងៗមកធ្វើវិភាគមុននឹងចាប់ផ្សាយការបង្រៀនល្បងនេះជាទូទៅ ក្នុងឆ្នាំនេះ (១៩៦៤) ។

នៅមានកម្មវិធីជំនួយមួយទៀតសំរាប់មាតាបិតា បានផ្សាយរៀងរាល់ថ្ងៃអាទិត្យ ចាប់តាំងពី១ឆ្នាំមកហើយ ។ បណ្តាកម្មវិធីដទៃទៀតដែលចូលក្នុងការបង្រៀនពិសេស យើងសូមលើកការផ្សាយ«ពត៌មានសម្រាប់អ្នកខ្វាក់»នឹង «សាលាតាមទូរទស្សន៍សំរាប់អ្នកថ្លង់»

(ពត៌មានអុយណេស្កូ ឧសភា ១៩៦៤)

# បំនួនអាគារសិក្សា សាស្ត្រាចារ្យនឹងសិស្ស ឆ្នាំ 1964

| | អាគារ (សាលាដាច់ពីអាគារ) | សាស្ត្រាចារ្យ (ពាក់កណ្ដាលពេល) | សិស្ស |
|---|---|---|---|
| សួនកុមារ . . . . . . | 7.372 (143) | 34.689 (4.759) | 855.539 |
| សាលាបឋមសិក្សា . . . . | 22.724 (3.891) | 340.839 (1.838) | 11.056.915 |
| សាលាមធ្យមសិក្សា . . . | 12.003 (644) | 246.547 (11.217) | 7.328.344 |
| សាលាឧត្តមសិក្សា . . . . | 3.711 (926) | 140.186 (22.621) | 3.281.474 |
| Collèges moyens . . . . . | 305 | 7.284 (8.057) | 107.714 |
| Collèges et Universités . . | 260 | 47.850 (19.419) | 727.104 |
| សាលាពិសេសសំរាប់មនុស្សខ្វាក់ . . . | 75 (3) | 2.176 (194) | 10.127 |
| សាលាពិសេសសំរាប់មនុស្សគ . . . | 97 (8) | 3.627 (133) | 20.180 |
| សាលាពិសេសសំរាប់មនុស្សមិនធម្មតា . . . | 74 (12) | 980 (62) | 8.288 |

បណ្ណាល័យ សារមន្ទីរ នឹងស្ថាប័នឯទៀតៗមានភារៈជាសំខាន់ក្នុងការអប់រំ ។ គិតមកដល់ខែកញ្ញា 1961 មានបណ្ណាល័យសាធារណៈចំនួន736 (សៀវភៅ 17.603.773 ក្បាល) ។ ក្នុង 12 ខែ មានមនុស្សម្ភៃប្រាំពីរលាននាក់បានចូលបណ្ណាល័យនេះ ។ មានសារមន្ទីរចំនួន 495 សួនសត្វ 43 អាងចិញ្ចឹមសត្វទឹងដាំដើមឈើ (l'aquarium) 60 នឹងសួនដាំដើមឈើ 39 ។

ក្នុងឆ្នាំ 1962 មាននិស្សិតបរទេសចំនួន 4.772 នាក់បានមកសិក្សាក្នុងមហាវិទ្យាល័យជប៉ុន ក្នុងនេះមានកូរ៉េ 2.439 នាក់ ចិន 1.115 នាក់ អាមេរិក 227 នាក់ ។

★

# ភារៈកិច្ចបីយ៉ាងដ៏សំខាន់

- ពង្រីកការអប់រំយុវជនតាមគ្រប់លំដាប់ថ្នាក់
- បង្រៀនមនុស្សពេញវ័យដោយបង្កើនការសិក្សាក្រៅសាលា
- អប់រំបង្កើតពលករជំនាញៗ នៅក្នុងមជ្ឈមណ្ឌលអប់រំវិជ្ជាជីវៈ

នៅឆ្នាំទទួលឯករាជ្យ ក្នុងគ.ស. ១៩៤៥ ចំនួនសិស្សដែលមានចុះឈ្មោះនៅក្នុងគ្រឹស្ថានសិក្សាចាប់ពីថ្នាក់បឋមសិក្សាទៅដល់មហាវិទ្យាល័យ មានមិនដល់ទាំងពីរលាននាក់ផង ។ លុះមកដល់ឆ្នាំ ១៩៦០ ចំនួននេះកើនដល់ទៅ ១០ លាននាក់ ។ ចំពោះប្រទេសមួយដែលមានមនុស្សជាងមួយរយលាននាក់នេះ លេខនៃចំនួនសិស្សប៉ុណ្ណេះឃើញនៅស្តួចស្តើងណាស់ ។ ប៉ុន្តែទោះម្តេចម្តា ក៏ការចំរើនល្អគួរលាស់បានសំរេចយ៉ាងសំបើមណាស់ហើយ ពិសេសគឺចំពោះផ្នែកបឋមសិក្សា ពីព្រោះភាគរយនៃជនដែលពុំចេះអក្សរ ដែលកាលពីមុនចម្បាំងលោកលើកទី ២ មាន ៩២,៩៣% នោះ ក្នុងឆ្នាំ ១៩៥៩ ចុះមកនៅត្រឹម ៤០,៦៦% ហើយក្នុងឆ្នាំ ១៩៦២ ចុះមកដល់ត្រឹម ២៥% ។

រដ្ឋាភិបាលមិនបានព្រងើយកន្តើយចំពោះសាធារណៈការដ៏ធំទូលាយដែលត្រូវបំពេញក្នុងវិស័យសាធារណៈសិក្សាធិការនេះទេ ព្រោះយល់ច្បាស់ណាស់ថាប្រជាជាតិ

ដែលទើបតែនឹងរួចអំពីការជិះជាន់នៃរបបអាណានិគមនិយម ត្រូវការចាប់ផ្ដើមផែនការបង្កើតសេដ្ឋកិច្ច ។ អាស្រ័យហេតុនេះហើយបានជាបញ្ហាអប់រំត្រូវបានបញ្ចូលទៅក្នុងកម្មវិធីនៃផែនការជាតិខាងការពង្រីកលូតលាស់សំរាប់រយៈ ៨ ឆ្នាំ ដែលអនុវត្តចាប់ពីឆ្នាំ១៩៦១ មក ។ ចំពោះផែនការនេះ គោលដៅសំខាន់គឺអនុវត្តទាំងស្រុងនូវច្បាប់សិក្សាជាកាតព្វកិច្ចដែលមានចុះក្នុងនិតិក្រមជាមូលដ្ឋានខាងការអប់រំពីឆ្នាំ ១៩៨០ ។

■ របបសិក្សាសព្វថ្ងៃឋិតនៅលើវិស័យបីយ៉ាងខុសគ្នា គឺ:

— ការអប់រំសិស្សដោយសុទ្ធសាធ ចាប់ពីសួនកុមារ(ថ្នាក់កូនក្មេងតូចៗ)រហូតដល់មហាវិទ្យាល័យ ;

— ការអប់រំមនុស្សធំ ហើយនឹងរាល់សកម្មភាពសំរាប់ប្រយុទ្ធនឹងភាពមិនចេះអក្សរ;

— និងការអប់រំខាងវិជ្ជាជីវៈសំរាប់បង្កើតគុណភាពរបស់អ្នកធ្វើការងារព្រមទាំងធ្វើឲ្យអ្នកអស់នេះទទួលនូវសមត្ថភាពថ្មីៗ ទៀតដែលប្រទេសជាតិត្រូវការ ។

# នៃសាធារណសិក្សា

មន្ទីររដ្ឋមន្ត្រីក្រសួងអប់រំជាតិនិងវប្បធម៌ ត្រួតត្រានឹងទាក់ទងរាល់សកម្មភាពទាំងនេះមែនហើយ ។ ប៉ុន្តែ សូមបញ្ជាក់ថា រដ្ឋពុំមានសិទ្ធផ្ដាច់មុខចំពោះការសិក្សាទេ ។ នៅមានអង្គការសាធារណៈឯកជនជាច្រើន ដែលរួបរួមគ្នាជួយជាកម្លាំងខាងសិក្សាធិការរបស់ប្រទេស ។ អង្គការទាំងនេះខ្លះទទួលនូវជំនួយជាឥណទានអំពីរដ្ឋាភិបាល ខ្លះទៀតចាត់ការដោយថវិកាផ្ទាល់របស់ខ្លួនតែម្ដង ។

មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញឥណ្ឌូណេស៊ីបានគ្រោងជាអាទិ៍ថា ពលរដ្ឋទាំងអស់មានសិទ្ធិចំពោះការសិក្សា ហើយរដ្ឋាភិបាលត្រូវទទួលភារៈរៀបចំនឹងកាន់កាប់របបនៃការ

សិក្សាដែលមានកំណត់ទុកនៅក្នុងច្បាប់ ។ របបការសិក្សាសព្វថ្ងៃឋិតនៅលើច្បាប់ជាមូលដ្ឋានខាងការអប់រំឆ្នាំ១៩៦០ដ៏ជាក់លាក់ដែលចែកជា ៤ ថ្នាក់ :

- ថ្នាក់មេតេយ្យសិក្សា
- ថ្នាក់បឋមសិក្សា
- ថ្នាក់មធ្យមសិក្សា
- និងថ្នាក់ឧត្តមសិក្សា

ច្បាប់នេះបានគ្រាន់បន្ថែមទៀតថា ការអប់រំមានសភាពវិសាមញ្ញបាននៅក្នុងករណីពិសេសៗ ប្រសិនបើមានការចាំបាច់ណាមួយ ។

នៅមានបទបញ្ញត្តិថ្មីមួយទៀតមកបំពេញនិតិក្រមដែលចែងពីការសិក្សាជាន់ខ្ពស់ គឺច្បាប់ឆ្នាំ ១៩៦១ ស្ដីអំពីការអប់រំនិងឧត្តមសិក្សា ។ ច្បាប់នេះបញ្ជាក់យ៉ាងច្បាស់នូវមុខងារនិងភារៈនៃវិជ្ជាស្ថានឧត្តមសិក្សា ។

ជាទូទៅការសិក្សាមានលក្ខណៈបំរុះ(ស្រីប្រុសរៀនចូលគ្នា) ។បឋមសិក្សាប្រព្រឹត្តទៅដោយឥតយកថ្លៃ ។ចំណែកឯផ្នែកមធ្យមសិក្សាវិញ តម្លៃនៃការសិក្សាគិតទៅតាមសមាមាត្រនៃបៀវត្ស ឬ ធនធានរកបានរបស់ឪពុកម្ដាយសិស្ស ។ នៅមហាវិទ្យាល័យ តម្លៃសិក្សាមានដូចគ្នាចំពោះនិស្សិតទាំងអស់ ។

បំណោទជាចំបងដែលចោទទៅលើអ្នកដឹកនាំ គឺបញ្ហាខ្វះថ្នាក់រៀននេះឯង ។ នេះហើយជាហេតុដែលនាំឲ្យក្មេងរាប់លាននាក់ ដែលរដ្ឋធម្មនុញ្ញបានជូនសិទ្ធិចំពោះការសិក្សា ហើយនោះនៅរកសាលារៀនគ្មាននៅឡើយ ។ ក្នុងរយៈកាល ១០ ឆ្នាំមុននេះ ការស្ថាបនាសាលារៀនទានសង្វាក់ក្នុង ១ ឆ្នាំ ៥០០ ហើយកាលពីចុងឆ្នាំ ១៩៥៩ ប្រទេសនៅខ្វះខាតសាលាជាងពីរម៉ឺនទៀតនៅឡើយ ។ បញ្ហាខ្វះខាតបែបនេះដោះស្រាយបានខ្លះ ដោយសារការប្រើថ្នាក់រៀនតែមួយបំពប់ថ្នាក់សិក្សាពីរខុសគ្នា គឺរៀនផ្លាស់គ្នា

ថ្នាក់មួយរៀនព្រឹក ថ្នាក់មួយទៀតរៀនល្ងាច ។

ដោយសារការខ្វះខាតថ្នាក់រៀនបែបនេះហើយ បានជាចំនួនបុគ្គលិកសិក្សាដែលនៅស្ដួចស្ដើងនៅឡើយក៏ដោយក៏អាចបង្គ្រប់ផ្នែកបឋមនិងមធ្យមសិក្សាបានល្មមដែរ ។ នៅផ្នែកឧត្ដមសិក្សាការខ្វះខាតសាស្ត្រាចារ្យមានចំពោះតែសាខាវិជ្ជាខ្លះប៉ុណ្ណោះ ពិ-សេសគឺក្នុងសាលាបច្ចេកទេស ។

■

នៅឆ្នាំ១៩៥៩-១៩៦០ សិស្សចំនួន៨.៥៥២ ៤៧៦នាក់រៀននៅក្នុងសាលាបឋមសិក្សាចំនួនប្រមាណជា ៣៧.០០០ ដែលឋិតនៅក្នុងប្រទេសទាំងមូល ។ នៅផ្នែកបឋមសិក្សា ការរៀនសូត្រចាប់ផ្ដើមពីអាយុ៦ឆ្នាំ ហើយមានរយៈកាល៦ឆ្នាំ ។ ផុតរយៈពេលសិក្សានេះសិស្សប្រឡងចេញដោយទទួលនូវសញ្ញាប័ត្រមួយដែលសាលារបស់ខ្លួនចេញឲ្យ ។

មធ្យមសិក្សាក៏មានរយៈពេល ៦ ឆ្នាំដែរ ហើយបែកជា ២ ភូមិ :

- មធ្យមសិក្សាបឋមភូមិ (៣ ឆ្នាំ)
- និងមធ្យមសិក្សាឧត្ដមភូមិ (៣ ឆ្នាំ)

មធ្យមសិក្សាបែកជាសាលារៀនវិជ្ជាទូទៅ និងគ្រឹស្ថានឯកទេសដូចជាសាលាបច្ចេកទេស (អគ្គិសនីបច្ចេកទេស, បច្ចេកទេសខាងគ្រឹស្ថាន, គ្រឿងយន្ត, ពាណិជ្ជកម្ម, សំណង់នាវា, ការងារពាណិជ្ជកម្ម ។ល។ ) ឬសាលាអប់រំវិជ្ជាជីវៈ (ដូចជាខាងជំនួញ, ការងារក្នុងផ្ទះ(arts ménagers) ការសិក្សាខាងសង្គមកិច្ច, ខាងមិតិសាស្ត្រ ។ល។ )

ដើម្បីរៀនសាលាមធ្យមសិក្សាបឋមភូមិបានសិស្សត្រូវប្រឡងចូល ។ ចំណែកឯការចូលរៀនមធ្យមសិក្សាជាន់ខ្ពស់វិញត្រូវកំណត់យកតាមលទ្ធផលនៃការប្រឡងចេញពីសាលាខាងលើ ។ នៅឆ្នាំ ១៩៥៩-១៩៦០ មានសិស្សជាង១លាននាក់រៀននៅក្នុងគ្រឹស្ថានមធ្យមសិក្សាមធ្យមភូមិ ។

តាមគោលការណ៍វិញ្ញាបនប័ត្រនៃសាលាមធ្យមសិក្សាមធ្យមភូមិ អាចឲ្យចូលរៀននៅឧត្តមសិក្សាបាន ។ ក៏ប៉ុន្តែដោយហេតុថា មានចំនួននិស្សិតចង់ចូលរៀនច្រើនពេកគេត្រូវសម្រាំងសមត្ថភាពដោយធ្វើការប្រឡងប្រជែងឲ្យចូលឧត្តមសិក្សាដូចជាឲ្យធ្វើវិញ្ញាសាពិសោធន៍ខាងចិត្ត-បច្ចេកវិជ្ជាមួយជាបន្ថែម ។

នៅថ្នាក់ឧត្តមសិក្សា ការអនុវត្តច្បាប់ជាធរមានឋិតនៅលើក្រសួងអប់រំជាន់ខ្ពស់និងខាងវិទ្យាសាស្ត្រ ។ ចំណែកឯសាលាជាន់មធ្យមនិងជាន់ទាប គឺឋិតនៅក្រោមកិច្ចត្រួតត្រានៃក្រសួងអប់រំមូលដ្ឋាននិងវប្បធម៌ ។

◙

តាមច្បាប់ឆ្នាំ ១៩៦១ ស្តីពីឧត្តមសិក្សា សាកលវិទ្យាល័យនីមួយៗ ចែកចេញជាសាខាទៅតាមអត្តភាពនិងឯកភាពនៃវិទ្យាសាស្ត្រ គឺបែកទៅជាផ្នែកមហាវិទ្យាល័យ ៤ គឺ:

ផ្នែកទី១ : មហាវិទ្យាល័យអក្សរសាស្ត្រ, ប្រវត្តិវិទ្យាគរុកោសល្យនិងមនុស្សវិជ្ជា ;

ផ្នែកទី២ : មហាវិទ្យាល័យសាសនវិជ្ជា និងចិត្តវិទ្យា ;

ផ្នែកទី៣ : សង្គមវិទ្យាសាស្ត្រ (sciences sociales) ដែលមាន : មហាវិទ្យាល័យច្បាប់, សេដ្ឋកិច្ច, វិទ្យាសាស្ត្រខាងនយោបាយ, ខាងការគ្រប់គ្រងសាធារណៈ និងខាងពាណិជ្ជកម្ម;

ផ្នែកទី៤ : វិទ្យាសាស្ត្រជាក់ស្តែងនិងបច្ចេកទេសដែលមាន : មហាវិទ្យាល័យខាងជីវវិទ្យា (biologie), វេជ្ជវិទ្យា (médecine) , សិល្បៈទន្ត (art dentaire), ឱសថវិទ្យា (pharmacie) , បសុវិទ្យា(vétérinaire), ធរណីវិទ្យា(agronomie) , គណិតវិទ្យា និងរូបវិទ្យា (maths et physique) សេដ្ឋវិទ្យា និងសាគរវិទ្យា (géologie et océanologie)

រយៈឆ្នាំសិក្សានៅឧត្តមសិក្សាកំណត់ជាទូទៅត្រឹម ៥ ឆ្នាំ លើកលែងតែខាងវេជ្ជវិទ្យាដែលមានរយៈសិក្សាដល់ទៅ ៦ ឆ្នាំកន្លះ ។

ក្រៅពីមន្ទីរពិសេសពីសំរាប់រ៉ាប់រងខាងបញ្ហាអប់រំ នៅមានក្រសួងច្រើនទៀត ដែលបានបង្កើតនូវសាលា ឬ ការបង្រៀនខ្លះដែលមានកំរិតវិជ្ជាត្រឹមមធ្យមសិក្សា ឬឧត្តមសិក្សា ដើម្បីនឹងហ្វឹកហ្វឺនបុគ្គលិករបស់គេឲ្យមានប្រសប់មានបច្ចេកវិជ្ជាក្នុងការងារនៃក្រសួងនីមួយៗនោះ ។ ដូចយ៉ាងក្រសួងកសិកម្ម បានបង្កើតសាលាកសិកម្ម; ក្រសួងសន្តិសុខ បានបង្កើតសាលាក្រមខណ្ឌប៉ូលិស; ក្រសួងធម្មការ បានបង្កើតសាលាគរុវិជ្ជាអ៊ីស្លាមសាសនា; ក្រសួងការពារប្រទេសគ្រប់គ្រងបណ្ឌិតសភាកងទ័ពជាតិ; ក្រសួងសុខាភិបាលបង្កើតសាលាឆ្មប ។ល។

ចំពោះការសិក្សាក្នុងឧត្តមភូមិ ដែលក្រសួងអប់រំគ្រប់គ្រង នៅក្នុងឆ្នាំ ១៩៥៨-៦០ មាននិស្សិតចុះឈ្មោះរៀនចំនួន ៧៥.៥០០នាក់ ក្នុងគ្រឹស្ថានផ្សេងៗដែលរដ្ឋាភិបាលអនុញ្ញាតិបើក គឺរៀននៅសាកលវិទ្យាល័យ, វិទ្យាល័យ, វិជ្ជាស្ថាន, បណ្ឌិតសភា ឬរៀននៅស្ថាប័នដទៃទៀតដែលមានរបៀបរៀបចំត្រូវគ្នាតាមរាជការ ។

នៅឆ្នាំ ១៩៦១ ប្រទេសឥណ្ឌូណេស៊ីមានសាកលវិទ្យាល័យ (université)រាជការចំនួន ១២ ។ សាកលវិទ្យាល័យសំខាន់ជាងគេបំផុតគឺសាកលវិទ្យាល័យ “ដ្យាការតា” ដែលមានមហាវិទ្យាល័យ ៨១ (81 facultés)។ សាកលវិទ្យាល័យនេះមាននិស្សិតរៀនចំនួន ៤០.០៩៨ នាក់ ។ ក្រៅពីសាកលវិទ្យាល័យ នៅមានវិជ្ជាស្ថានខាងបច្ចេកទេសរបស់រាជការ ២ ; មានវិជ្ជាស្ថាន ៤៣ មានកំរិតវិជ្ជាស្មើនឹងបណ្ឌិតសភា ហើយដែលគ្រប់គ្រងដោយក្រសួងរាជការផ្សេងៗ ហើយនឹងមានវិជ្ជាស្ថានឯកជនខាងឧត្តមសិក្សា ឬ ខាងសាសនាចំនួន ៩១ ដែលក្នុងចំណោមនេះមានវិជ្ជាស្ថាន ៣០ ទទួលជំនួយពីរដ្ឋាភិបាល ។

◙

ការអប់រំធ្វើការបច្ចេកទេស ក៏គឺជាមុខងារសំខាន់មួយទៀតរបស់ក្រសួងអប់រំ ។ ហេតុដូច្នេះហើយទើបគេឃើញមានសាលាអប់រំវិជ្ជាជីវៈនិងបច្ចេកទេសសំរាប់គ្រប់កំរិត

វិជ្ជា ពិសេសគឺក្នុងកំរិតមធ្យមសិក្សា ។ ប៉ុន្តែ ចំពោះការអប់រំបែបនេះការចាំបាច់របស់ប្រទេស តំរូវឲ្យដោះស្រាយជាបន្ទាន់តាមវិធីផ្សេងទៀត ដើម្បីឲ្យនិយោជិតដែលគ្មានការងារ មានគ្រប់វ័ណ្ណពជការ និងមានអាយុច្រើនហើយ អាចមានសមត្ថភាពនឹងបច្ចេកវិជ្ជាកាន់តែសំខាន់ឡើងៗ ។

ចំពោះរបបទូទៅនៃការសិក្សាក្រសួងពជការនិមួយៗ រកមធ្យោបាយដោយផ្ទាល់ខ្លួន ដើម្បីអប់រំនិយោជិតពជការរបស់ខ្លួន ។ នៅក្នុងឆ្នាំ ១៩៥៩ ក្រសួងការងារបានបង្កើតផ្នែកសាលាអប់រំពិសេសសំរាប់អប់រំការងារដល់និយោជិត ។

ក្រសួងអប់រំវិជ្ជាជីវៈបំពេញសកម្មភាពដោយបិតនៅលើគោលបំណងពីរបែបគឺ:

– បង្កើនសមត្ថភាពខាងមុខវិជ្ជាជីវៈដល់អ្នកធ្វើការ;

– ហើយពិសេសបង្រៀនអ្នកដែលពុំទាន់មានការធ្វើឲ្យចេះការងារបច្ចេកទេសណាមួយ ដើម្បីផ្តល់ទៅឲ្យក្រសួងនានាជួយខាងការបង្កើនសេដ្ឋកិច្ចជាតិ ។

ក្រសួងអប់រំវិជ្ជាជីវៈរំពៃមើលការអនុវត្តនៃកម្មវិធីបង្រៀននៅក្នុងឧស្សាហកម្ម ដើម្បីធ្វើឲ្យកើនដល់ការបង្កើតផល ។ កម្មវិធីដែលចេញអនុវត្តនៅក្នុងឆ្នាំ ១៩៥៨ ដោយមានអ្នកជំនាញការបរទេសជួយផង សំដៅទៅរកការបង្កើនកោតផលតាមវិធីធ្វើការត្រួតត្រានឹងការដឹកនាំឲ្យកាន់តែប្រសើរឡើង ។ កម្មវិធីនេះមានវត្ថុធាតុ ៣ យ៉ាង គឺ:

– អប់រំឲ្យចេះការងារ

– អប់រំឲ្យចេះខ្លូការទាក់ទងរវាងការងារទាំងឡាយ

– នឹងវិធីអប់រំខាងសិប្បិយការ ។

ក្នុងកំឡុង ២ ឆ្នាំ គឺពីខែឧសភា ១៩៥៨ ដល់ឧសភា ១៩៦០ អ្នកជំនាញការបរទេសជួយបង្កើតបានតាំងអស់ទូរ:

តទៅទំព័រ ២៥

តារាងនៃការរីកចំរើនខាងសិក្សាធិការនៅប្រទេសឥណ្ឌូណេស៊ី

| ការចាត់ថ្នាក់ សាលា | មុនបំបាំង 1939 - 1940 ឆ្នាំសិក្សា | | | ពេលជប៉ុនត្រួតត្រា ពីថ្ងៃ 31-10-1942 ដល់ 1945 | | | ក្រោយឯករាជ្យ 1959 - 1960 ឆ្នាំសិក្សា | | |
|---|---|---|---|---|---|---|---|---|---|
| | សាលា | សិស្ស | សាស្ត្រាចារ្យ | សាលា | សិស្ស | សាស្ត្រាចារ្យ | សាលា | សិស្ស | សាស្ត្រាចារ្យ |
| 1. សាលាបឋមសិក្សា . . . . | 21.455 | 2.359.492 | 48.364 | 13.459 | 1.598.862 | 31.901 | 37.376 | 8.552.476 | 205.860 |
| 2. សាលាមធ្យមសិក្សា បឋមភូមិ | | | | | | | | | |
| ក) សិក្សាទូទៅ . . . . . | 84 | 15.533 | 744 | 16 | 5.502 | 179 | 4.358 | 781.374 | 28.978 |
| ខ) សិក្សាបច្ចេកទេស . . . | 734 | 38.680 | 2.281 | — | — | — | 1.131 | 80.747 | 9.097 |
| 3. សាលាមធ្យមសិក្សាមធ្យមភូមិ | | | | | | | | | |
| ក) សិក្សាទូទៅ . . . . . | 32 | 7.810 | 476 | 4 | 1.430 | 52 | 1.203 | 180.495 | 13.656 |
| ខ) សិក្សាបច្ចេកទេស . . . | — | — | — | — | — | — | 320 | 10.317 | 2.701 |
| 4. ឧត្តមសិក្សា: មហាវិទ្យាល័យ (វិទ្យាល័យ) . . . . | 4 | 1.246 | 125 | — | — | — | 92 | 75.58 | 3.698 |

ក្នុងកំណើតរបស់វា ការប្រយុទ្ធទល់នឹងភាពមិនចេះអក្សរមិនអាចនឹងបំបែកឲ្យដាច់ចេញពីការប្រយុទ្ធដើម្បីឯករាជ្យបានឡើយ ដោយហេតុថា ចំពោះជនជាតិឥណ្ឌូ-ណេស៊ី ការប្រយុទ្ធទល់នឹងភាពមិនចេះអក្សរនេះ គឺគ្រាន់តែជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយជាច្រើនទៀត សំរាប់រំដោះខ្លួនចេញពីការជិះជាន់បរទេសនឹងសំរាប់ប្រមូលផ្តុំប្រជាជនជាមួយនឹងកម្លាំងការកសាងជាតិ ។

# របៀបពិសេសមួយនៃការប្រយុទ្ធ

## ទល់នឹងភាពមិនចេះអក្សរ

### ពលរដ្ឋទាំងអស់ត្រូវចេះអាននឹងចេះសរសេរនៅដំណាច់ឆ្នាំ 1964

នៅសម័យអាណានិគម ៩៤ភាគរយនៃជនជាតិឥណ្ឌូណេស៊ី សុទ្ធតែជាអ្នកមិនចេះអក្សរ ; ក៏ប៉ុន្តែ ចាប់តាំងពីកំណើតនៃចលនាជាតិនិយម(Mouvement nationaliste) — ២០ ឧសភា ១៩០៨ដែលរៀងរាល់ឆ្នាំ គេបានធ្វើបុណ្យខួបរំឭកថាជាថ្ងៃជាតិភ្ញាក់រឭកនោះមក — អ្នកដឹកនាំទាំងឡាយនៃចលនា ក៏បានចាប់ផ្តើមការប្រយុទ្ធទល់នឹងសេចក្តីល្ងង់ខ្លៅនៃប្រជារាស្ត្រនៅក្នុងកៀនកោះដែលឆ្ងាយៗជាងគេបំផុត ។ អ្នកដឹកនាំទាំងឡាយបង្រៀនសរសេរនិងអានផង បណ្តុះក្នុងរូបពលរដ្ឋម្នាក់ៗនូវសេចក្តីស្នេហាស្រុកទេសផង ។ ដូច្នេះបានជានៅពេលដែលបដិវត្តន៍បានផ្ទុះឡើង កិច្ចការរបស់អស់

លោកក៏បានទៅជាដងថ្មីមួយដ៏ខ្លាំង ដើម្បីញុំាងឧត្តមគតិជាតិនិយមឲ្យមានជ័យជំនះឡើង ។

សព្វថ្ងៃនេះ នៅក្នុងក្របខណ្ឌនៃការព្រាងពង្រីកទូទៅនិងតាមផែនការ(total et planifié) ការប្រយុទ្ធនឹងភាពមិនចេះអក្សរបានគោរពគោលការទាំងឡាយដូចតទៅនេះ ៖

– ភូមិនិមួយៗ ត្រូវល្បងសាងការបំរុងចំរើន ពង្រីកផ្ទៃក្នុងនៃសង្គមរបស់ខ្លួនដោយខ្លួនឯង ។

– ភូមិនិមួយៗ ត្រូវធ្វើអាជីវកម្មនូវធនធានធម្មជាតិទាំងឡាយរបស់ខ្លួន ។

– នាយកនៃភូមិនិងក្រុមអភិបាលភូមិត្រូវបានទទួលការអប់រំហ្វឹកហ្វឺនមួយដ៏សមរម្យ ។

ការប្រយុទ្ធទល់នឹងភាពមិនចេះអក្សរ ដែលជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយទាំងឡាយ ដើម្បីនឹងអប់រំសង្គមត្រូវខិតខំធ្វើឲ្យកើតមានឡើងក្នុងរូបអ្នកភូមិម្នាក់ៗ នូវគំនិតឯកភាពជាតិ គំនិតស្វ័យសកម្មភាព និងគំនិតទទួលខុសត្រូវ ។

ត្រូវមានគំនិតឯកភាព ដោយហេតុថា ក្នុងរូបបុគ្គលម្នាក់ៗ គំនិតជាតិនិយមត្រូវបានកើតឡើងដោយការបណ្តុះនូវមនោសញ្ចេតនាទុកចិត្តចំពោះខ្លួនឯងជាដំបូង ។ យ៉ាងនេះ ប្រជាកស្រ្តទាំងមូលអាចនឹងដឹងខ្លួនថាបានរួបរួមគ្នាក្នុងការស្ថាបនាជាតិ និងស្ថាបនាវប្បធម៌ជាតិ ។

ត្រូវមានគំនិតស្វ័យសកម្មភាព ដោយហេតុថា មានតែសម្បទានឹងធ្វើការដោយខ្លួនឯងរបស់ពលរដ្ឋម្នាក់ៗ តាមមធ្យោបាយទាំងឡាយផ្ទាល់ខ្លួនឯង ហើយដោយគ្មានរំពានអ្នកដទៃតែប៉ុណ្ណោះទេ ដែលធ្វើឲ្យពលរដ្ឋម្នាក់ៗ មានសេរីភាពពិតប្រាកដបាន ។

ត្រូវមានគំនិតទទួលខុសត្រូវ ដោយហេតុថា ជនជាតិឥណ្ឌូណេស៊ីម្នាក់ៗ ត្រូវតែដឹងថាបញ្ហាទាំងឡាយរបស់ខ្លួន ត្រូវតែបានដោះស្រាយដោយខ្លួនឯង ពោលគឺ

ពុំមែនដោយមនុស្សដទៃម្នាក់ទៀត ឬដោយប្រជាជនដទៃមួយទៀតឡើយ ។

កិច្ចការជាតិដ៏ធំទូលាយនេះមានបំណងជាដំបូងបង្អស់នឹងបង្រៀនពលរដ្ឋម្នាក់ៗឲ្យចេះអាន នឹងចេះសរសេរ ក្នុងពេលវេលាដ៏ខ្លីបំផុត; ប៉ុន្តែ កិច្ចការមិនមែនចប់តែត្រឹមនេះទេ ។ គឺត្រូវផ្សព្វផ្សាយនូវដំបូន្មានទាំងឡាយ ដែលអាចនឹងចង្អុលប្រាប់ប្រជាជនថា តើត្រូវលើកកំរិតជីវភាព នឹងបង្កើនផលិតផល យ៉ាងដូចម្ដេច ហើយតើត្រូវអប់រំប្រជាជនដើម្បីនឹងដឹកនាំគេទៅកាន់ស្វ័យភាព យ៉ាងដូចម្ដេចទៀតផង ។

ដោយហេតុថា ការប្រយុទ្ធទល់នឹងភាពមិនចេះអក្សរគឺជាបញ្ហាជាតិ ពលរដ្ឋម្នាក់ៗមានករណីយកិច្ចនឹងចូលរួមក្នុងការប្រយុទ្ធនេះ ។ នៅស្រទាប់ខ្ពស់ខាងលើ ការប្រយុទ្ធនេះបានត្រូវដឹកនាំដោយ «ស្ថាប័ននៃការអប់រំប្រជាជន» (Institution de l'éducation populaire) ដែលស្ថិតនៅក្រោមឱវាទក្រសួងអប់រំជាតិនឹងវប្បធម៌ ។ អង្គការនេះធ្វើសហការជាមួយអ្នកដឹកនាំឃុំហើយបង្កើតក្នុងឃុំនិមួយៗនូវគណៈកម្មាធិការអប់រំប្រជាជន ដែលការៈជាទូទៅគឺអប់រំប្រជាជន ហើយមានការៈជាពិសេសគឺបង្រៀនប្រជាជនឲ្យចេះអាននឹងចេះសរសេរ ។

ដើម្បីនឹងធ្វើការដ៏ធំនេះ និយោជិតបច្ចេកទេស ១.៦៥០ នាក់ នឹងនិយោជិត

### អនុសទ្ទានក្រមនយោបាយ

Bhinneka Tunggal Ika
ឯកភាព ក្នុងពហុភាព (បាវចនាឥណ្ឌូណេស៊ី)

«Indonesia Baja» មហាឥណ្ឌូណេស៊ី (ភ្លេងជាតិ)

Pantja Sila បញ្ចសីលា (ទស្សនមូលភាពនៃរដ្ឋ):
ជឿអាទិទេព, ជាតិនិយម, មនុស្សជាតិ (ឬជាអន្តរជាតិនិយម, ប្រជាធិបតេយ្យ, យុត្តិធម៌សង្គម ។

Gotong-Rojong គំនិតសង្គ្រោះគ្នានឹងគំនិតសហគមន៍ ។

Madjelis Permusjawaratan Rakjat Sementara សមាជប្រជាជនបណ្ដោះអាសន្ន

Dewan Pertimbangan Agung ក្រុមប្រឹក្សាខ្ពស់បំផុតរបស់រដ្ឋ ។

Dewan Perantjang Nasional ក្រុមប្រឹក្សានៃផែនការជាតិ ។

រដ្ឋបាល ៨.០០០ នាក់ បានស្ថិតនៅ សព្វថ្ងៃនេះក្នុងគ្រប់តំបន់នៃប្រទេសឥណ្ឌូណេស៊ី ។ និយោជិតទាំងនេះឲ្យតែដំបូន្មានបច្ចេកទេសស្ដីអំពីរបៀបបង្រៀនអក្សរ និងអំពីការអភិ-បាល និងការរៀបចំការសិក្សានេះតែប៉ុណ្ណោះទេ ។

និយាយរួម ការប្រយុទ្ធទល់នឹងភាពមិនចេះអក្សរនេះ មានទិដ្ឋភាពបីគឺ ៖

– ការបង្រៀនអក្សរឡាតាំងដល់មហាជនតាមរយៈឃ្លាខ្លីៗងាយៗ (១) ។ ថេរ–វេលានៃការសិក្សាមានពី ៣ ទៅ ៤ សប្ដាហ៍ ដោយរៀនបីលើក ហើយក្នុងមួយលើកៗ រៀនមួយម៉ោងកន្លះ ក្នុងមួយសប្ដាហ៍ ។ មនុស្សណាដែលចេះអានហើយអាចនឹងបង្រៀនអក្សរ ដល់អ្នកដទៃតទៅទៀត ។

– ពង្រីកនូវសមត្ថភាពខាងប្រាជ្ញារបស់បុគ្គលទាំងឡាយ ជាអាទិ៍ដោយប្រើសមត្ថភាពនៃការអាននឹងការសរសេររបស់គេ ដើម្បីជាគុណប្រយោជន៍ដល់សង្គម ដើម្បីកសាងសង្គមភូមិ ។

– ពង្រីកផ្នែកវប្បធម៌នៃការសិក្សានេះ ដែលមានគោលបំណងនឹងនាំប្រជាជនឥណ្ឌូណេស៊ីឆ្ពោះទៅកាន់សង្គមមួយដែលមានយុត្តិធម៌ និងមានសេចក្ដីចំរុងចំរើន ។

ដើម្បីនឹងសំរេចគោលដៅទាំងពីរខាងក្រោយនេះ ការសិក្សាប្រតិបត្តិ ( les cours pratiques) ក៏បានត្រូវតាក់តែងឡើង ដោយមានជំនួយរបស់សាស្ត្រាចារ្យទាំងឡាយដែលបានទទួលការអប់រំរៀបចំជាមុនហើយផង ។ ការសិក្សានេះ បានប្រព្រឹត្តទៅអស់ពេល ៣ ខែ ដោយរៀន ៣ ដង ហើយក្នុងមួយដងៗ មួយម៉ោងកន្លះ ក្នុងមួយសប្ដាហ៍ ។

ក៏ប៉ុន្តែ កាលណាការប្រយុទ្ធទល់នឹងភាពមិនចេះអក្សរបានចប់ក្នុងតំបន់ណាមួយហើយ ការងារអប់រំក៏នៅតែមិនទាន់ចប់នៅឡើយទេ ។ តមកទៀត គេត្រូវតែតាម

(១)– នៅប្រទេសឥណ្ឌូណេស៊ី ក្នុងការអនុវត្តិនៃជីវភាពសម័យ អក្សរឡាតាំងត្រូវបានគេយកមកប្រើប្រាស់រហូតដល់ទៅក្នុងប្រាមភាសាផង ។

សកម្មភាពអប់រំរបស់សង្គមទៀត ៖ នេះគឺជាការងារដែលធ្លាក់មកលើគណៈកម្មាធិការ «មិត្ត! ចូរក្រោកឡើង (Fellow up)» ហើយដែលស្ថិតលើគោលការតទៅនេះ ៖

— ផ្តល់ចំពោះបុគ្គលទាំងឡាយ ដែលទើបនឹងរៀនអាននឹងរៀនសរសេរ នូវលទ្ធភាពសំរាប់លំអចំណេះថ្មីៗ ទាំងនេះបន្តទៅទៀត ហើយជាអាទិ៍គឺជំរុញគេទាំងឡាយនេះឲ្យអាន ។

— ស្គាល់សេចក្តីត្រូវការខាងសម្ភារៈចាំបាច់សំរាប់ការអាន ក្នុងតំបន់ ឬ ភូមិនីមួយៗ ។

**ឧស្សាហកម្មប្រេងកាតឥណ្ឌូណេស៊ី គិតជាលេខ**

- ការជីក : ក្នុងមួយឆ្នាំ អណ្តូងប្រមាណជា 60, ភាគច្រើនបានផល ។
- ផលិតកម្ម : 22,5 លានតោនក្នុងឆ្នាំ 1962 ផ្ទឹមនឹង 21,2 ក្នុងឆ្នាំ 1961 គឺជា 2,4% ពីផលិតកម្មសាកលលោក ។
- ផង្រុកធម្មជាតិ : 1.500 លានតោន គឺជា 3,5% ពីផង្រុកធម្មជាតិសាកលលោក ។
- ការចំរាញ់ : បំណុះ 14 លានតោន ក្នុងមួយឆ្នាំ គឺជា 1% ពីចំណុះសាកលលោក ។
- ការនាំចេញ : 18,5 លានតោន ក្នុងឆ្នាំ 1962 (3% ពីការនាំចេញសាកលលោក) ។ អ្នកទិញសំខាន់ៗ: សរអា ជប៉ុន អូស្ត្រាលី ហ្វីលីពីន ។
- ការប្រើប្រាស់ក្នុងស្រុក: 4 លានតោន ។

មានតែធ្វើយ៉ាងនេះទេ ទើបគេអាចនឹងសង្ឃឹមថាបានរៀបចំផ្លូវទៅកាន់ព្រឹត្តិការណ៍ (l'avènement) នៃសង្គមសង្គមនិយមឥណ្ឌូណេស៊ីពិតប្រាកដ ។ មធ្យោបាយដ៏ប្រសើរៗ ដើម្បីនឹងបន្តការអប់រំប្រជាជនសំរាប់ចំរុងចំរើនភូមិ នឹងពង្រីកមនសិការជាតិ (la conscience nationale) មានដូចតទៅនេះ៖ ការបោះពុម្ពផ្សាយនូវសៀវភៅគ្រប់បែបជាអាទិ៍នូវកាសែតប្រចាំខែទាំងឡាយ, ការចាត់ចែងការប្រជុំក្នុងភូមិដែលគេអាចនឹងអានហើយនឹងស្តាប់នូវសន្និសីទ, ការចាត់ចែងការហាត្ថកម្ម, ការបង្កើតភូមិគំរូ ដែលក្នុងភូមិនោះ គេបង្រៀននូវវិជ្ជាមេផ្ទះ នឹងយកចិត្តទុកដាក់ចំពោះក្មេងៗ ។ល។

ហេតុមកដល់នឹងថ្ងៃនេះ តំបន់ទាំងឡាយនៃប្រទេសឥណ្ឌូណេស៊ី ដែលមិនទាន់បានរំដោះចេញពីនឹមមិនចេះអក្សរនៅឡើយ គឺតំបន់អៀរីយ៉ង់ខាងលិច បរណេអូខាង

លិចនិងខាងកើត ហើយនិង ម៉ូលុគ (les Moluques) ។ ប៉ុន្តែឥឡូវ ការងារនេះ បានមកដល់ទីបំផុតហើយ ៖

តាមពិត បើតាមប្រសាសន៍នៃលោកប្រធានាធិបតីនៃសាធារណរដ្ឋ ប្រទេសទាំងមូលត្រូវបានរំដោះចេញពីភាពមិនចេះអក្សរនេះ នៅដំណាច់និទាឃរដូវ ឆ្នាំ ១៩៦៤ នេះ លើកលែងតែតំបន់អៀរីយ៉ង់ខាងលិចចេញ ។ ដូច្នេះការងារមួយយ៉ាងធំសំបើមដែលធ្វើឡើងបានដោយកម្លាំងដ៏វែងនឹងអំណត់អត់ធ្មត់ ហើយធ្វើឡើងក្នុងប្រទេសមួយដែលមានមនុស្ស ១០០ លាននាក់ ក៏នឹងបានចប់សព្វគ្រប់ហើយ ។ គេអាចនឹងពោលបានយ៉ាងប្រាកដថា នេះគឺជាសមិទ្ធិមួយក្នុងចំណោមសមិទ្ធិដ៏ល្អៗ ជាងគេទាំងឡាយ នៃប្រទេស ឥណ្ឌូណេស៊ីឯករាជ ។

តពីទំព័រ ១៨

- អ្នកត្រួតពិនិត្យទូទៅ ២ ៩១២ នាក់
- អ្នកបង្ហាត់ការងារ ១៥៨ –
- នឹងគ្រូបង្ហាត់ការងារ ២៧ –

បច្ចុប្បន្ននេះ អ្នកបង្ហាត់នាយកជាតិឥណ្ឌូណេស៊ី បានឡើងមកជំនួសអ្នកជំនាញការបរទេសទាំងឡាយដែលចប់បេសកកម្មរបស់ខ្លួនហើយចេញពីប្រទេសទៅហើយ ។ អ្នកជំនាញការជាតិទាំងនេះទទួលភារៈតែឯងក្នុងការអនុវត្តកម្មវិធីសំរាប់ការកែចំរើនរបស់ប្រទេសតទៅមុខ ។

ស្រង់ពីសារពត៌មាន

Le Monde diplomatique-ឧសភា 1964



# ទស្យាសាស្ត្រ នឹង ការរៀន

## សិស្សភ្ញាក់រលឹក

**ចេង យា** សាស្ត្រាចារ្យ វិទ្យាល័យព្រះសុរិយាវង្ស ទី២

យើងខ្ញុំរាល់គ្នាសិក្សាកាម　　កុលបុត្រធ្វើតាមក្រិត្យវិន័យ
ជិតាសព្វចិត្តជាស្រី　　ឃ្មាតខ្មីរៀនសូត្រដោយម៉ឺនម៉ាត់ ។
ធម៌ខ្ជិលយើងខ្លាក់ចោលឲ្យដាច់　　ធម៌ធ្វេសប្រញាប់ខំលះកាត់
ទុកនៅនាំកើតគុណវិបត្តិ　　បេ្តជ្ញាកំចាត់កុំបន្ទាយ ។
ថ្ងៃខែចេះតែកន្លងផុត　　ទឹកឃើញចង់ស្មុតហើយគិតស្តាយ
ឈរមុខកញ្ចក់មើលរាងកាយ　　វិវត្តប្រែកឆ្ងាយតែរាល់ថ្ងៃ ។
រីពេលវេលាជាទ្រព្យធន　　បានដល់ពួកជនចេះកែខៃ
ធ្វើពេលវេលាជាបច្ច័យ　　ជីវិតគេថ្លៃល្អបវរ ។
កិច្ចការប្រែក្លាយជាប្រាក់កាស　　អ្នកខំធ្វើណាស់មិនដែលក្រ
អ្នកខ្ជិលប្រអូសមិនមែនល្អ　　រស់នៅត្រដរតាមវាសនា ។
សិស្សណាខ្សះខ្សាហ៍ខំសូត្ររៀន　　ស្ដាប់ដំបូន្មានគ្រូអាចារ្យ
សិស្សនោះតែងបានផលថ្លៃថ្លា　　មាតាបិតានឹងសប្បាយ ។
សិស្សណាដែលខ្ជិលមន្ទិលគ្រប់　　រៀនឈប់រៀនឈប់ចិត្តនឿយណាយ
នាំឲ្យកើតទុក្ខឪពុកម្ដាយ　　ពិបាកខ្វល់ខ្វាយស្ទើរតែស្លាប់ ។
ខ្លះខំរៀនដែរនៅតែល្ងង់　　ថាព្រោះពូជពង្សប្រាជ្ញាអាប់
ពោលយ៉ាងដូច្នេះខុសចំណាប់　　គ្មានច្បាប់ឯណាថែនដូច្នេះ ។

រៀនគ្មានរបៀបគ្មានដឹងថ្នាក់ គ្មានចិត្តទុកដាក់មិនឆាយបេះ
បើចិត្តមិននឹងមិនផែលផេះ តែងខ្វះបំណេះជាមិនខាន ។
ម្យ៉ាងខ្វះគំនិតគិតមិនយល់ នាំក្តីល្វិតល្វល់មកដល់ប្រាណ
តែខ្វះគំនិតរៀនម្តេចបាន កុំស្មាននាំស្មាញសាញដល់ចាស់ ។
តាំងចិត្តជាសិស្សឲ្យប្រាកដ រៀនសូត្រម៉ត់ចត់ទើបបេះច្បាស់
តែរៀនស្ទើរៗ ក្មេងរហ័ស បេះច្បាប់មិនច្បាស់គ្មានបានការ ។
ខ្វះទៅរៀនសូត្រឃើញតែមុខ យកខ្លួនទៅទុកក្នុងសាលា
បណ្តោយអារម្មណ៍ដើរសង្ហារ ទុកឲ្យកាយាចាំស្តាប់គ្រូ ។
អង្គុយភ្លេតភ្លេនដូចខសគល់ ធ្វើម្តេចនឹងយល់ចាំបានយូរ
ទៅផ្ទះខទ្ទេញចាំមាត់រូ លុះគ្រូហៅសួរភ្លេចស្ទើរអស់ ។
តាំងខ្លួនជាសិស្សកុំវង្វេង នាំគ្នាដើរលេងសើចឡេះឡោះ
ឃើញស្រីញញឹមញញើមញ៉ាក់ញ៉េះញ៉ោះ មិនគិតស្រណោះដល់ឪម៉ែ ។
សិស្សណាវង្វេងតាមផ្លូវនេះ គំនិតសំគះពិបាកកែ
រៀនសូត្រមិនទាន់បានមួយខែ ទៅផ្ទះរកម៉ែតារលុយទៀត ។
មាតាបិតាពុំបានយល់ ជួមបុត្រនិម្មលឥតមារយាទ
មិនដឹងជាកូនដើរបោលមៀត ថែមប្រាក់ឲ្យទៀតគ្មានរំពឹង ។
យើងខ្ញុំសិក្សាតាមកុលបុត្រ គោងគេចឲ្យផុតពីក្បួននឹង
គួរដែកពិនិត្យគិតសញ្ជឹង រំពឹងអាណិតចិត្តម៉ែឪ ។
គាត់ខំសន្សំញើសស្រោក ទុកគ្រាន់ឲ្យអ្នកទិញសៀវភៅ
ខោអាវបៀកពាក់ភ្ញានត្រឹមត្រូវ លោកខ្លាចប្រុសពៅមិនដូចគេ ។
មួយត្រូវតាំងចិត្តឲ្យខ្ជាប់ខ្ជួន ពីរត្រូវកែខ្លួនកុំទំនេរ
បីត្រូវរិះគិតកុំរៀចរេរ ទើបគេសរសេរជាអ្នកល្អ . . . . ។

# ទំព័រមួយថ្មី នៃវិទ្យាសាស្ត្រ សាកលលោក

## ▣ សន្និបាតវិទ្យាសាស្ត្រមួយជាប្រវត្តិ

កាលពីថ្ងៃទី២១សីហា១៩៦៤ សមាជវិទ្យាសាស្ត្រមួយដ៏មានលក្ខណៈជាប្រវត្តិបានបើកសម័យប្រជុំនៅធានីប៉េកាំង ។ នៅក្នុងសភាប្រជាមានិតជាតិដែលបើកសម្ពោធសមាជវិទ្យាសាស្ត្រ គេសង្កេតឃើញអ្នកវិទ្យាសាស្ត្រជាង ៣៩០ នាក់មកពី ៤៤ ប្រទេសក្នុងទ្វីបទាំងបួន (អាស៊ី, អាហ្វ្រិក, អាមេរិកឡាទីន និងអូសេអានី)។ គណៈប្រតិភូនៃប្រទេសកម្ពុជាយើង មានលោក ផ្លុក ឆាត់ លោកស្រី ទិព្វ ម៉ម លោក ហ៊ីង អ៊ីន់ និងលោក កូ ស៊ុំអ៊ុយ ។ នៅក្នុងកម្មវិធីដ៏ទូលំទូលាយនៃសមាជ មានគ្រោងទុកនូវការអានសេចក្ដីរាយការណ៍ជិត ៣០០ ច្បាប់ ស្ដីអំពីវិទ្យាសាស្ត្រធម្មជាតិនិងវិទ្យាសាស្ត្រសង្គម ។

អ្នកដែលមករួមប្រស្រ័យសមាជទាំងប៉ុន្មាន ថ្វីត្បិតតែមានសំបុរស្បែកនិងសំបុរសំលៀកបំពាក់ខុសៗគ្នា សុទ្ធតែបានសំដែងនូវសេចក្ដីទុកចិត្តយ៉ាងពោរពេញនិងមានគោលបំណងចារឹកទំព័រមួយថ្មីនៃប្រវត្តិវិទ្យាសាស្ត្រសាកលលោកគ្រប់ៗគ្នា ។

## ពិធីបើកសម័យ

នៅក្នុងពិធីបើកសម័យ មានអានទូរលេខនឹងសារលិខិតសាទរទាំងឡាយ នៃសម្តេចព្រះនរោត្តម សីហនុ ព្រះប្រមុខរដ្ឋកម្ពុជា នៃលោក ហូ ជីមិញ ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម នៃលោក គីម អុីល-សេន នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ នៃលោក ស៊ូការណូ ប្រធានាធិបតីឥណ្ឌូណេស៊ី នៃលោក អាមេដ បែន បែឡា ប្រធានាធិបតីនៃសាធារណរដ្ឋអាល់ហ្សេរីប្រជាធិបតេយ្យប្រជាមានិត នៃលោក ង្វៀន ហ៊ូយថូ ប្រធាននៃគ្រុមប្រឹក្សាគណៈកម្មាធិការកណ្ដាលនៃរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង នឹងនៃបណ្ឌិត ស៊ូបង់ទ្រីយ៉ូ ឧបនាយករដ្ឋមន្ត្រីឥណ្ឌូណេស៊ី ។

នៅក្នុងឱកាសនោះ មានអ្នកដឹកនាំគណៈប្រតិភូនឹងអ្នកវិទ្យាសាស្ត្រ៣៧នាក់ បានឡើងថ្លែងយោបល់គោរពសមាជហើយចាត់ទុកសមាជនេះថាជាការរួមប្រជុំនៃសាមគ្គីភាពនឹងសហប្រតិបត្តិការរវាងអ្នកវិទ្យាសាស្ត្រនៃទ្វីបអាស៊ី អាហ្វ្រិក អាមេរិកឡាទីននឹងអូសេអានី ។ ពាក្យទាំងឡាយបានបញ្ជាក់ថា «វិទ្យាសាស្ត្រនៃទ្វីបទាំងបួននេះមានអនាគតត្រចះត្រចង់ណាស់» ។ ហើយបានសំដែងនូវសេចក្ដីទុកចិត្តចំពោះការដែលសមាជនេះ បានធ្វើឲ្យវិទ្យាសាស្ត្រនឹងវប្បធម៌នៃទ្វីបទាំងបួនបានទាក់ទងគ្នាទៅវិញទៅមក ហើយរីកលូតលាស់ឡើងប្រកបដោយជោគជ័យ ។

## ការអាន នឹងការពិភាក្សាសេចក្ដីរាយការណ៍

ចាប់តាំងពីថ្ងៃ ២២ សីហាមក វិមានវិទ្យាសាស្ត្រ (ខាងពាយព្យក្រុងប៉េកាំង) ដែលជាកន្លែងសមាជវិទ្យាសាស្ត្រ បានឃើញសកម្មភាពមួយយ៉ាងសំបើម ។ សេចក្ដីរាយការណ៍សំរាប់ពិភាក្សាមានចែកជាប្រាំបីវិស័យគឺ ៖ វិទ្យាសាស្ត្រធម្មជាតិ; វិទ្យាសាស្ត្រអនុវត្ត; វិទ្យាសាស្ត្រកសិកម្ម; វិទ្យាសាស្ត្រពេទ្យ; វិទ្យាសាស្ត្រនយោបាយនឹងច្បាប់; សេដ្ឋកិច្ចនយោបាយ; តរុកោសល្យ; និរុត្តិវិទ្យានឹងអក្សរសាស្ត្រ; ទស្សនវិទ្យា

នឹងប្រវត្តិវិទ្យា ។ អ្នកវិទ្យាសាស្ត្រនៃប្រទេសទាំងឡាយធ្វើជាអធិបតីនៃសម័យប្រជុំម្តងម្នាក់ៗ ហើយគួរយោបល់នឹងការពិសោធន៍គ្នាទៅវិញទៅមកដោយស្មោះត្រង់ជាទីបំផុតដើម្បីឆ្ពោះទៅរកការចេះដឹងថ្មី ។

## ◘ ពិធីបិទសម័យ

សមាជវិទ្យាសាស្ត្រក្រុងប៉េកាំង ឆ្នាំ១៩៦៤ ដែលបានប្រព្រឹត្តទៅអស់រយៈពេល១១ថ្ងៃ បានបញ្ចប់កិច្ចការរបស់ខ្លួននៅថ្ងៃ១១សីហា ឆ្នាំ១៩៦៤ ដោយជោគជ័យ ក្នុងវិមានសភាប្រជាជន ។ សេចក្តីជូនដំណឹងមួយផ្សាយចេញពីសមាជបានឲ្យដឹងថា សមាជមួយទៀតនឹងបើកធ្វើឡើងនៅក្រុងប៉េកាំងក្នុងឆ្នាំ ១៩៦៨ ។

នៅក្នុងពិធីជប់លៀងដែលធ្វើក្នុងល្ងាចថ្ងៃបិទសមាជ លោកប្រធានាធិបតី លីវ សាវ ជី បានថ្លែងជាអាទិ៍ថា ៖ «ជ័យជំនះនៃសមាជនេះ បង្កើតជាមហាជោគជ័យនៃវិទ្យាសាស្ត្ររបស់ប្រជាជនក្នុងទ្វីបទាំងបួន ក៏ដូចជាមហាជោគជ័យមួយនៃវិទ្យាសាស្ត្ររបស់គ្រប់ប្រជាជនក្នុងសាកលលោកដែរ» ។

## ◘ លទ្ធផលជាទីពេញចិត្ត

សកម្មភាពសំខាន់ៗនៃសមាជឋិតនៅលើការអាននិងការពិភាក្សានូវសេចក្តីរាយការណ៍ ២៩៩ច្បាប់ ស្តីអំពីវិទ្យាសាស្ត្រធម្មជាតិនិងវិទ្យាសាស្ត្រសង្គម ។

សកម្មភាពទាំងឡាយបានប្រព្រឹត្តទៅជាប្រាំបីគណៈកម្មការគឺ គណៈកម្មការនៃវិទ្យាសាស្ត្ររូបនឹងធម្មជាតិ (sc. physiques et nat.) គ.ក នៃវិទ្យាសាស្ត្រខាងវិស្វករ(sc. de l'Ingénieur) គ.ក.នៃកសិកម្ម គ.ក.នៃវិទ្យាសាស្ត្រពេទ្យ(sc. médicales) គ.ក.នៃវិទ្យាសាស្ត្រនយោបាយនឹងច្បាប់ (sc. polit.et jurid.) គ.ក សេដ្ឋកិច្ច គ.ក.គរុកោសល្យ ភាសានឹងអក្សរសាស្ត្រ គ.ក.ទស្សនវិទ្យានឹងប្រវត្តិវិទ្យា ។ សមាជិកនៃគណៈកម្មាធិការនីមួយៗត្រូវបានជ្រើសតាំងឡើងក្នុងចំណោមអ្នកវិទ្យាសាស្ត្រនៃវិស័យជាមួយគ្នា ដោយរើសសមាជិកម្នាក់សំរាប់ប្រទេសនីមួយៗ ។ សេចក្តីរាយការណ៍មួយចំនួនធំ ដែលបានអាននៅសមាជបានបង្ហាញកំរិតយ៉ាងខ្ពស់នូវសមិទ្ធិ

វិទ្យាសាស្ត្រក្នុងទ្វីបទាំងបួន ។ មានលទ្ធផលខ្លះបានទទួលការអនុវត្តន៍យ៉ាងទូលំទូលាយ ហើយមានលទ្ធផលខ្លះទៀតប្រកបទៅដោយសារសំខាន់ខាងទ្រឹស្តីយ៉ាងធំ ។

> ប្រទេសនឹងតំបន់ទាំង៤៤ ដែលបានទៅរួមប្រស្រ័យសមាជវិទ្យាសាស្ត្រនៅប៉េកាំង ឆ្នាំ ១៩៦៤ :
>
> **au Symposium de Pékin de 1964 :**
>
> (ពីថ្ងៃ ២១ ទៅ ៣១ សីហា ១៩៦៤)
>
> អាហ្គានីស្ថាន, បណ្ឌិតសភាវិទ្យាសាស្ត្រអាហ្វ្រិកខាងកើត(កេនីញ៉ា, អ៊ូហ្គង់ដា, សហសាធារណរដ្ឋតង់ហ្គានីកានឹងហ្សង់ហ៊្សីបា), អាល់ហ្សេរី, អង់ហ្គោឡា, សាធារណរដ្ឋអារ៉ាប់រួម, អូស្ត្រាលី, ភូមា, បូលីវី, ប៊ូរុនឌី, កម្ពុជា, សិរីលង្កា, ស៊ីលី, ចិន, កូឡុំប៊ី, កុងហ្គោ (ប្រាសាវីល), សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ, គុយបា, ដាហូម៉េ, ហ្គាណា, ហ្គីណេ, ឥណ្ឌូណេស៊ី អៀរ៉ាក, ជប៉ុន, ហ្សរដានី, លីបង់, ម៉ាល់ហ្គាស, ម៉ាលី, ម៉ារុក, មិចស៊ិច, ណេប៉ាល់, នីហ្សេរីយ៉ា, នូវ៉ែលហ្សេឡង់, ប៉ាគីស្ថាន, សេណេហ្គាល, ស្សៀរ៉ាឡេអូន, សូម៉ាលី, ស៊ូដង់, ស៊ីរី, ថៃ, សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម, វៀតណាមខាងត្បូង នឹង យេម៉ែន ។

នៅក្នុងសមាជ អ្នកវិទ្យាសាស្ត្រទាំងឡាយបានផ្លាស់ប្តូរយោបល់គ្នាដើម្បីរកផ្លូវមួយច្បាស់លាស់សំរាប់ការរីកលូតលាស់នៃវិទ្យាសាស្ត្រមួយឯករាជ គឺថាវិទ្យាសាស្ត្រដែលបំរើការលូតលាស់ខាងផលិតកម្មនិងបំរើការលើកឋានៈជីវភាពប្រជាជន ដោយពឹងផ្អែកជាអាទិ៍លើកំឡាំងផ្ទាល់របស់ខ្លួន ហើយព្រមជាមួយនោះដែររីកចំណងសាមគ្គីភាពនិងសហប្រតិបត្តិការរវាងអ្នកវិទ្យាសាស្ត្រទាំងឡាយ នៅលើមូលដ្ឋានសមភាពនៃអត្ថប្រយោជន៍ទៅវិញទៅមក ។ នៅក្នុងសមាជ ហេតុការណ៍បានបង្ហាញជាថ្មីម្តងទៀតថាយុគសម័យដែលចក្រពត្តិនិងអាណានិគមនិយមក្របក្រសោបវិទ្យាសាស្ត្រផ្តាច់មុខនោះបានកន្លងផុតទៅហើយ ។ ហើយហេតុការណ៍ក៏បានបង្ហាញម៉្យាងទៀតថា ប្រជាជននៃទ្វីបទាំងបួន បន្ទាប់ពីបានរំដោះខ្លួនផុតពីការជិះជាន់របស់ចក្រពត្តិនិងអាណានិគមមក មានសមត្ថភាពយ៉ាងពេញលេញនឹងពង្រីកវិទ្យាសាស្ត្រនៅក្នុងប្រទេសរបស់ខ្លួន ហើយមានសមត្ថភាពយ៉ាងពេញលេញនឹងខិតខំតាមឲ្យទាន់កំរិតយ៉ាងខ្ពស់បំផុតនៃវិទ្យាសាស្ត្រសាកលលោក ។

# សល្យវិទូចិនបានដេរដៃ

## របស់កម្មករម្នាក់ដែលបាក់ដាច់ពីគ្នា

## ឲ្យបានជាប់គ្នាវិញ

សល្យវិទូ(les chirurgiens ) នៅសាំងហៃ បានដេរភ្ជាប់ដោយជោគជ័យ នូវដៃរបស់កម្មករម្នាក់ដែលដាច់ចេញពីគ្នាទៅហើយ ។ អស់លោកទាំងនេះនៅក្នុងក្រុមជាមួយគ្នាក្នុងមន្ទីរពេទ្យប្រជាជនលេខ៦ ដែលក្នុងឆ្នាំ១៩៦៣ បានដេរប្រគប់ដៃ ( la main) មួយរបស់លោកវ៉ាំង ស៊ូអិនប៉ូ ដែលដាច់ចេញពីដៃទៅហើយឲ្យជាប់នឹងដៃលោកវិញ ។ វ៉ាំង ស៊ូអិនប៉ូ ជាកម្មករដំឡើងគ្រឿងយន្ត ។

កាលពីថ្ងៃ ២៦ វិច្ឆិកា ឆ្នាំទៅនេះ ក្នុងការពិនិត្យម៉ាស៊ីនរបស់ខ្លួនឡើងវិញ សារី ស៊ីវ ឡុង(ធ្វើការនៅរោងចក្រគីមី វូតស៊ីង ក្រុងសាំងហៃ)បានធ្វេសប្រហែសចំពោះបទបញ្ជាខាងសន្តិសុខ ។ ដៃឆ្វេងរបស់ស៊ារីក៏ត្រូវអ័ក្សម៉ាស៊ីន(l'axe du moteur)ត្រចាក់ហើយដាច់ប៉ាត់នៅចំងាយ ៨ សង់ទីម៉ែត្រអំពីស្មា ។ ពេលនោះស៊ារីក៏ត្រូវរបួសត្រង់ក្បាល ហើយនឹងទ្រូងថែមទៀត ។ នៅក្នុងស្ថានភាពដ៏អាសន្ននេះ ស៊ារីក៏ត្រូវបានគេដឹកទៅមន្ទីរពេទ្យយ៉ាងរហ័ស នៅពេលជាបន្ទាប់មក ។ នៅទីនោះ លោកវេជ្ជបណ្ឌិត ធិន ប៊ុងវ៉ី, សៀន យុនស៊ីង, ប៉ាវ យេស៊ិ នឹង វ៉ាំង យ៉ិន ក៏រាប់ដេរភ្ជាប់ដៃនេះភ្លាម នៅប្រាំនាទីក្រោយមក ។

សព្វថ្ងៃនេះ លុះថាវេលា៥ខែបានកន្លងផុតទៅ អ្នករបួសក៏អាចលានឹងបត់ដៃដែលទើបនឹងដេរភ្ជាប់ អាចលើកដៃស្ទាបក្បាល ហើយនឹងអាចលើកវត្ថុផ្សេងៗ ទំងន់ ១ គីឡូទៀតផង ។

ការនេះបញ្ជាក់នូវវឌ្ឍនភាពមួយថ្មី ខាងសល្យវិទ្យាផ្នែករបួស នៃប្រទេសចិនៗ ពិនិត្យមើលសព្វគ្រប់ទៅ បញ្ហាទាំងឡាយដែលសល្យវិទូបានដោះស្រាយលើកនេះ គឺជាបញ្ហាស្មុគ្រស្មាញជាងបញ្ហាក្នុងករណីទី១ ដែលលោកទាំងឡាយបានដេរភ្ជាប់ប្រអប់ដៃទៅនឹងកំភួនដៃនោះ ទៅទៀត ។

អ្នករបួសលើកនេះ បានស្ថិតនៅក្នុងស្ថានភាពយ៉ាប់ជាងមុនខ្លាំងណាស់ ព្រោះបណ្តាលមកពីការឈឺចាប់ខាងមុខរបួសដៃ មុខរបួសក្បាល និងទ្រូង ៗ បើត្បិតតែយ៉ាងនេះក៏ដោយ ក៏សល្យវិទូទាំងឡាយចាប់ធ្វើការនេះភ្លាម ដោយសេចក្តីទុកចិត្ត ហើយដោយផ្អែកទៅលើការពិសោធន៍ក្នុងករណីមុន និងផ្អែកទៅលើការរកឃើញថ្មីៗទៀតនៃការស្រាវជ្រាវ តាំងពីពេលនោះមក ។ ការប៉ុនប្រសប់របស់លោកទាំងឡាយ បានត្រូវសេចក្តីប្រឹងប្រែង ប្រកបដោយសហការយ៉ាងល្អវិសេសនៃបុគ្គលិកមន្ទីរពេទ្យទាំងអស់គ្នាជួយគបស្ងួបផង ។

លទ្ធផលគឺជាលិកា (les tissus) ទាំងឡាយនៃដៃអ្នករបួស បានស្រួលបួលឡើងវិញ ក្នុងរយៈពេលមួយយ៉ាងខ្លីគួរឲ្យកត់សំគាល់ គឺគ្មានការពេលដាលណាមួយកើតឡើងឡើយ ហើយក្នុងករណីនេះ ថែមទាំងគ្មានពងដោរដែលច្រើនតែកើតឡើងជាញឹកញយ ក្រោយពេលដេរភ្ជាប់ទៀតផង ។ ករណីនេះ បានផ្តល់នូវការពិសោធន៍មួយដ៏ថ្លៃថ្លាក្នុងសិល្បៈដាំភ្ជាប់អវយវៈរបួសដាច់ទាំងឡាយ ។



អស់លោកវេជ្ជបណ្ឌិត ឆិន ចុងវី
(ខាងឆ្វេង) នឹង សៀន យុនស៊ីញ (ខាងស្តាំ) ហើយនឹងអ្នករបួស



ជាដំបូងសល្យវិទូបានលាងសំអាតចុងឆ្អឹងដើមដៃ ( l'humérus) ដែលបែកបាក់ រួចហើយក៏តភ្ជាប់ចំណែកដាច់ៗគ្នានេះ ដោយដាក់ដង្កៀបមួយក្នុងខួរឆ្អឹង (une broche intramédulaire) ។ ចំណែកខូចខាតទាំងឡាយនៃសរសៃដៃ (les parties endommagées) ត្រូវបានគេកាត់យកចេញពីមុខតំណ ហើយយកទៅតភ្ជាប់ដោយសរសៃជើង (la veine saphène) មួយកំណាត់ៗ ។ ការដាំភ្ជាប់សរសៃឈាមខ្មៅស្វ័យប៉្លាស្ទិច (la greffe veineuse auto plastique) ត្រូវបានគេដេរភ្ជាប់នៅនឹងកន្លែង ដោយខ្សែស្រូត្រមួយយ៉ាងឆ្មារជាទីបំផុត ។ សរសៃឈាមខ្មៅបាស៊ីលិច (la veine basilique) ក៏ត្រូវបានកែកុន ដោយការដាំសរសៃឈាមខ្មៅស្វ័យប៉្លាស្ទិចដែរ ។ សរសៃឈាមខ្មៅពីរដៃទៀតត្រូវបានតភ្ជាប់គ្នាដោយបំពង់ធ្វើពីលោហធាតុតង់តាលីយ៉ូម (des raccords de tantallium) ដែលបង្កើតឡើងជាពិសេសសំរាប់ការនេះ ។ នេះហើយជាបុព្វហេតុធំ ដែលនាំមិនឲ្យពងដោរ ។

ស្អែកឡើង គេក៏បានចាប់វះក្បាល ដើម្បីយកឈាមដែលកកនៅក្រោមសំបកលលាដ៍ក្បាល (la dure-mère) ចេញ ។

ដោយមកពីរបួសនៅដៃធ្ងន់ពេក គេពុំបានរៀបរយកែកុនសរសៃវិញ្ញាណ (les nerfs) ទាំងឡាយនៅដំណាក់ទី១ទេ ។ ការរៀបចំសរសៃវិញ្ញាណស្វ័យប៉្លាស្ទិចត្រូវបានធ្វើនៅពេលក្រោយៗមក ជាបន្តបន្ទាប់គ្នា ។ សព្វថ្ងៃនេះ សរសៃវិញ្ញាណដែលគេបានដេរភ្ជាប់ឡើងវិញ បានលូតលាស់តាមរបៀបមួយគួរជាទីពេញចិត្ត ។ ការពិ-

និត្យថ្មីៗ បានបង្ហាញនូវសញ្ញានៃការជាសះជាប្រក្រតីឡើងវិញ រហូតដល់ទៅ១២សង់ទីម៉ែត្រ ខាងក្រោមកែងដៃ ។

សាវ ស៊ីវឡុង សព្វថ្ងៃនេះ កំពុងតែបានទទួលការព្យាបាលរឹត (le traitement de physiothérapie et de massage) ដើម្បីសំរួលដំណើរដៃឡើងវិញ ។

បានជាសល្យវិទូនៃមន្ទីរពេទ្យប្រជាជនលេខ៦ ក្រុងសាំងហៃ បានទទួលជោគជ័យថ្មីនេះទៀត ពីព្រោះអស់លោកបានបដិសេធចោលយ៉ាងប្តូរផ្តាច់ នូវគំនិតដែលគិតថា «អាត្មាអញគ្រប់គ្រាន់ហើយ» ក្រោយពីជ័យជំនះទី១មក ។ អស់លោកទាំងឡាយដែលប្រកបទៅដោយគំនិតបដិវត្តន៍ នឹងចង់បំរើប្រជាជនពិតៗ បានបន្តនឹងសំគីជីកការស្រាវជ្រាវទាំងឡាយឲ្យកាន់តែជ្រាលជ្រៅទៅៗ លើបច្ចេកទេសនៃការដាំភ្ជាប់អវយវៈដែលបាក់ដាច់ទៅហើយ ។



សព្វថ្ងៃនេះ ក្រុមស្រាវជ្រាវពិសេសមួយ បានបង្កើតឡើងហើយ ។ លោកវេជ្ជបណ្ឌិត ឆេន ចុងវ៉ី, ស៊ិន យុងស៊ីង ព្រមទាំងអស់លោកឯទៀតៗដែលបានសិក្សាអំពីការប៉ះប៉ុនសរសៃឈាមតូចៗ ក្នុងរូបសត្វ បានជំរុញការពិសោធន៍របស់លោកឲ្យកាន់តែលឿនទៅមុខទៅៗ ។

លោកបានទាំងធ្វើការពិនិត្យពិសេសមួយអំពីបុព្វហេតុនៃពងដោរ ក្រោយពេលវះកាត់នឹងអំពីវិធីបង្ការការពងដោរនេះថែមទៀតផង ។

អ្នកជំនាញការល្បីឈ្មោះទាំងឡាយ នៃក្រុងសាំងហៃ ខាងការវះកាត់ប្រព័ន្ធវិញ្ញាណ (neurachirurgie) ខាងការវះកាត់មុខរបួស (chirurgie traumatique) ខាងការវះកាត់បស្សាវមគ្គ (chirurgie urologique) និងខាងវេជ្ជវិទ្យាផ្ទៃក្នុង (médecine interne) បានធ្វើការពិគ្រោះមួយដ៏វែង ជាមួយសល្យវិទូទាំងឡាយនៃមន្ទីរពេទ្យលេខ១៦ ហើយបានផ្តល់នូវជំនួយមួយយ៉ាងថ្លៃថ្លា ។

អ្នកបច្ចេកទេសទាំងឡាយ នៃរោងចក្រធ្វើសម្ភារៈវះកាត់ ក៏បានផ្តល់វិភាគទានរបស់ខ្លួន ដោយបានធ្វើម្ជុលវះកាត់ ធ្វើប្រដាប់សំរាប់ដេរភ្ជិតទាំងឡាយ និងសម្ភារៈប្រើប្រាស់ទាំងអស់ឲ្យកាន់តែល្អឡើងៗ ថែមទៀត ។

★



1

សូមមិត្ត តំណាង នៅវិទ្យាល័យ-អនុវិទ្យាល័យនិមួយៗ មេត្តាផ្ញើមកជូន គណៈកម្មាធិការនាយក ឲ្យបានឆាប់រហ័សទៀងទាត់ នូវដំណឹងអំពីសុខភាពនៃមិត្តយើងផង (អាពាហ៍ពិពាហ៍ កូនចៅ ជំងឺឈឺថ្កាត់ គ្រោះថ្នាក់ ការប្រឡងជាប់ . . . ) ។

# វិទ្យាសាស្ត្រខ្លីៗ ...

## ម៉ាស៊ីន សំរាប់សរសេរអក្សរភ្លេង

នៅប្រទេសអង់គ្លេស គេទើបនឹងបង្កើតម៉ាស៊ីនសរសេរអក្សរភ្លេងមួយឈ្មោះ «មីញូស៊ីគ្រីទែ (Musikriter)» ។ ម៉ាស៊ីននេះមានប្រដាប់ស្វ័យប្រវត្តិ សំរាប់វាយបង្កើតអក្សរ ២០ ប្លែកៗគ្នា ។ ការបង្កើតបន្ទាត់សំរាប់សរសេរសញ្ញាភ្លេង ពុំមែនជាការពិបាកអ្វីទេ ប៉ុន្តែអក្សរភ្លេង ដូចជាស (blanche), ខ្មៅ (noire), croche, dièze, bémol, ។ល។ ក៏ត្រូវបានបោះពុម្ពយ៉ាងដិតច្បាស់លាស់ដែរ ។

ដើម្បីសរសេរអក្សរភ្លេងម៉ាស៊ីននេះមានប្រដាប់ជំនួយពីរយ៉ាង ៖ ប្រដាប់សំរាប់បញ្ចេញអក្សរភ្លេង ហើយនិងប្រដាប់សំរាប់សំគាល់សង្វាក់(ការផ្សាយរបស់យូណេស្កូ)

## រង្វាន់នៃការប្រឡងប្រជែងបទភ្លេងអន្តរជាតិ

រង្វាន់លេខមួយនៃការប្រឡងប្រជែងខាងតែងបទភ្លេង ដែលក្រុមប្រឹក្សាភ្លេងអន្តរជាតិ និងសមាគមមិត្តភ្លេងជាតិអូទ្រីស បានបង្កើតឡើង ត្រូវបានទៅអ្នកតែងបទជាតិប៉ូឡូញ ឈ្មោះ វីតុល លុយតូស្លាវស្គី(witold lutoslawski) ។ រង្វាន់នេះមានតម្លៃ ៣០ ០០០ ស៊ុលិញ (ប្រហែលជា ៦.០០០ ហ្វ្រង់ថ្មី) ។ រង្វាន់ទី២, ២០ ០០០ ស៊ីលិញ ត្រូវបានលោក វីលីយ៉ាម វ៉ាល់តុន ជាតិអង់គ្លេស ។ ឯរង្វាន់ទី ៣, ១២.៥០០ ស៊ុលិញ ត្រូវបានទៅលោក ប៉ុទែ ម៉ាស្វែល-ដាវី ជាតិអង់គ្លេស ។

នៅក្នុងឱកាសប្រឡងប្រជែងនេះ វង់ភ្លេង៣៩នៃប្រទេស២២បានលេងភ្លេងមហោរី របស់អ្នកតែងសម័យបច្ចុប្បន្ន ។ បទភ្លេងទាំងនេះ ទើបនឹងលេងជាលើកដំបូងបង្អស់ ក្នុងឆ្នាំ ១៩៦១-៦២ ។ ក្រោមអធិបតីភាពនៃលោក អ៊ែប៊ែរ៉ុន កាក៉ស្ហាន់ គណៈមេប្រយោគអន្តរជាតិ២ មួយនៅវីយែន មួយនៅ ប៉ារី បានចាត់ការរើសរកអ្នកត្រូវបានរង្វាន់ ។ ស្នាដៃ៣ដែលត្រូវបានរង្វាន់ ហើយដែលនឹងត្រូវលេងនៅថ្ងៃទី១៨ មិថុនា១៩៦៤ នៅពេលសមោសរ ក្នុងឱកាសបុណ្យនៅ

វីយ៉ែននោះគឺ៖

—concerto សំរាប់តន្ត្រីនៃលោក លុយ-ត្វូឡាវស្គី

—symphonie លេខ២របស់លោករ៉ាល់-គុន នីង

- fantasia របស់លោក ម៉ាស្វែល ដាវី

(ការផ្សាយ យូណេស្កូ)

◘

## មនុស្សកង្កែបជួយសង្គ្រោះសត្វឆ្លាម

នៅក្នុងកន្លែងចិញ្ចឹមត្រី នៅស៊ីដំណី ក្នុងប្រទេសអូស្ត្រាលី សត្វឆ្លាមជាច្រើនបាន ធ្វើកូដកម្មមិនស៊ីម្ហូបអាហារសោះ ពីព្រោះ សត្វទាំងនេះត្រូវគេយកមកទុកឲ្យរស់នៅក្រៅ សមុទ្រ ក្រហមដែលជាទីលំនៅរបស់វាៗ ដើម្បីនឹងធ្វើឲ្យសត្វឆ្លាមដ៏ថ្លៃថ្លាទាំងនេះ (ឆ្លាមរស់ៗសង់ទីម៉ែត្រថ្លៃ១រៀល!) បាន សប្បាយចិត្តឡើងវិញ អ្នករក្សាទីចិញ្ចឹមនេះ បានពឹងផ្អែកលើមនុស្ស-កង្កែប៤នាក់ៈ ដោយ សារអំណត់អត់ធន់ អ្នកមុជទឹកទាំង៤នាក់ ក៏បានផ្តល់អាហារដល់សត្វឆ្លាមទាំងនេះ ៗ

ទីចិញ្ចឹមត្រីនេះមានចំណុះលើសពីមួយលានលីត្រ ៗ គេបញ្ចូលទឹកសមុទ្រទៅក្នុងទីនេះ ដោយតំរង់ ៗ កន្លែងនេះមានត្រីនិងអណ្តើកសមុទ្រចំនួន ២.០០០ ដែលមាន ១០០ បែបប្លែកៗគ្នា ៗ

◘

## ឆ្អឹងខ្នងដំរីនៅរូម៉ានី

ក្នុងពេលជីកដីរកបុរាណវត្ថុនៅជិតអូលតេនី បុរាណវិទូ (le paléontologue) បានរកឃើញឆ្អឹងដំរីមួយ ដែលឋិតនៅតាំងពីយុគសម័យទី ៤ ម៉្លេះ (quarternaire) ៗ ក្នុងចំណោមឆ្អឹងនឹងភ្លុកជាច្រើន មានអដ្ឋិសន្ធិលិកមួយ មានកំពស់៣ម៉ែត្រ ឋិតនៅយ៉ាងគង់វង្ស ៗ គេសំគាល់ថាជាដំរី នៃទិសខាងត្បូង ៗ នេះជាដំរីទី៤ដែលគេបានរកឃើញនៅក្នុងពិភពលោក (ការផ្សាយរបស់ យូណេស្កូ)

◘

## ការប្រមូលមើមដំឡូងបារាំងដោយខួរអេឡិចត្រូនិច

នៅប្រទេសអេកុស គេបានពិសោធប្រើម៉ាស៊ីន ប្រមូលមើមដំឡូងបារាំងមួយប្រកបទៅដោយគ្រឿងប្រដាប់អេឡិចត្រូនិច ៗ

ម៉ាស៊ីននេះ អាចសំគាល់នូវសភាពប្លែកគ្នា របស់ ដំឡូង ដុំថ្ម និងដុំដី ។ គេបានសំរេចលទ្ធផល៩៨ %។ អ្នកបង្កើតម៉ាស៊ីនទំនើបនេះជាភ្នាក់ងារពងការនៃមន្ទីររដ្ឋមន្ត្រីកសិកម្ម នៅតេកុស ។ (ការផ្សាយរបស់ យូណេស្កូ)

▣

## LES NOUVELLES TECHNIQUES DE L'ENSEIGNEMENT: UNE EXPOSITION A LA MAISON DE L'UNESCO

Un nouveau type d'appareil avec écran incorporé, qui permet de montrer en projection continue un film en couleurs sans qu'il soit nécessaire d'interrompre la séance pour le rembobiner, a été présenté à l'exposition d'auxiliaires audiovisuels qui a eu lieu récemment à la Maison de l'Unesco à Paris. En dehors de ce projecteur, on pouvait y voir des machines à enseigner, des «laboratoires» pour l'enseignement des langues et des démonstrations de TV en circuit fermé. (Cette exposition était organisée à l'occasion de la réunion internationale d'éditeurs de manuels scolaires, convoquée par l'Unesco du 22 au 26 juin).

L'appareil de projection «sans fin», qui emploie des bandes des 8 millimètres, est aujourd'hui en usage courant en Angleterre, où il est utilisé dans quelque 1.600 écoles. Ces films ,les uns d'une durée de trois à cinq minutes, les autres de vingt à trente minutes, servent à l'enseignement des sciences, des mathématiques, ou des langues. Ainsi, dans l'enseignement du français, une série de douze bandes de 4 à 5 minutes, montre des scènes de la vie quotidienne d'une famille française type: dans le métro, dans les magasins, au cours d'une partie de campagne, au bureau, et ainsi de suite.

Le «laboratoire» pour l'enseignement des langues consiste en un magnétophone et une série de bandes: à l'aide d'écouteurs, l'élève suit la leçon, des pauses étant prévues pour lui permettre de répéter, à son micro, ce qu'il vient d'entendre. La bande est divisée en deux, une moitié étant réservée au cours proprement dit qui est indélébile, alors que les réponses de l'élève peuvent être effacées. Ainsi ce dernier est en mesure de répéter la leçon jusqu'à ce qu'il soit satisfait de ses propres réponses; ou, lorsqu'il s'agit d'un dispositif à plusieurs écouteurs, jusqu'à ce que le maître décide de passer à la leçon suivante.

La machine à enseigner la plus élémentaire comporte un rouleau de questions et de réponses qui passent devant un voyant: chaque rouleau contient 200 cardres. Les séries présentées à l'exposition comprenaient des cours de grammaire anglaise, d'algèbre et de mathématiques, ainsi que des exposés élémentaires d'astronautique. Parmi les appareils plus perfectionnés, on remarquait une machine automatique qui projetait sur un petit écran incorporé à l'appareil des questions ainsi que le corrigé des réponses.

Outre ces spécimens d'auxiliaires techniques de l'enseignement moderne, l'exposition de la Maison de l'Unesco présentait plusieurs centaines de livres scolaires de production récente, notamment relatifs aux sciences, aux mathématiques et aux langues vivantes. (*Informations Unesco*)

---

2

សូមមិត្តទាំងឡាយ មេត្តាជាប់អារម្មណ៍ អំពីការជួយផ្ដល់ពត៌មានសទ ទុកឱ្យមិត្តយើង ហើយនឹងអំពីអត្ថបទសំរាប់ទស្សនាវដ្ដីយើងឱ្យមែនទែន ។